# វគ្គទី ៣
# ប្រទេសកម្ពុជាក្នុងភ្លើងសង្គ្រាម
# ( ទសវត្សរ៍ឆ្នាំ ១៩៧០ )

កាលនោះនៅខែ មីនា ១៩៧០ នៅពេលដែលប្រជាជាតិខ្មែរទាំងមូល កំពុងរៀបចំជារៀងរាល់ថ្ងៃនូវពិធីគោរពព្រះវិញ្ញាណក្ខន្ធនៃសម្ដេចព្រះសង្ឃរាជ ជួន ណាត ។ នៅពេលនោះហើយដែលប្រវត្តិសាស្ត្រនៃប្រជាជាតិកម្ពុជាយើងបានប្រែទំព័រថ្មីពីទំព័រសន្តិភាព និង ស្ថិរភាពធ្លាក់ទៅក្នុងទសវត្សរ៍ដ៏ខ្មៅងងឹតដែលប្រជារាស្ត្ររងទុក្ខវេទនាឥតឈប់ឈរ ដោយសារសង្គ្រាមបំផ្លិចបំផ្លាញដ៏រ៉ាំរ៉ៃ និង ដោយសាររបបប្រល័យពូជសាសន៍ ។ នោះគឺជាសម័យកាលដែលជាតិខ្មែរត្រូវហូរឈាម និង រងទឹកភ្នែកឥតល្ហែល្ហើយ ។ ពាក្យចាស់និយាយថា "អ្នកធំស្លាប់ផែនដីរង្គើរ" ។ ពាក្យចាស់នេះ ប្រហែលជាលេចចេញនៅជំនាន់ដើម នៅពេលព្រះមហាក្សត្រសុគតម្ដងៗ តែងមានការដណ្ដើមរាជ្យគ្នា ។ ពួកយើងធ្លាប់រៀនតាមសៀវភៅប្រវត្តិសាស្ត្រតាំងពីក្មេងៗមកថា ប្រទេសខ្មែរយើងពុំសូវមានការផ្ទេរអំណាច ឬ ការផ្ទេររាជសម្បត្តិ ពីព្រះមហាក្សត្រមួយអង្គទៅមួយអង្គទៀតដោយសន្តិវិធីទេគឺ ជាញឹកញាប់ការផ្លាស់ប្ដូរនោះច្រើនធ្វើឡើងតាមការធ្វើចំបាំងរាំងជល់ ។ ទោះបីជាសម្ដេចព្រះសង្ឃរាជ ជួន ណាត ពុំមែនជាព្រះមហាក្សត្រសោយរាជ្យក៏ដោយ ក៏ការយាងចូលទិវង្គតរបស់ព្រះអង្គ អាចរាប់ថាជាប្រផ្នូលអាក្រក់មួយរបស់ប្រជាប្រជាជាតិយើងដែរ ។

តាមពិត សម្ដេចព្រះសង្ឃរាជ ជួន ណាត ជាឥស្សរជនដ៏ខ្ពង់ខ្ពស់មួយរូបដែលប្រជាជាតិខ្មែរសំដែងនូវការគោរពចំពោះព្រះអង្គ មិនមែនត្រឹមតែជាស្ដេចសង្ឃ

ធម្មតានោះទេ តែព្រះអង្គគឺ ជាអ្នកប្រាជ្ញខ្មែរមួយរូប ដែលបានធ្វើពលិកម្មព្រះជន្មទាំងស្រុង ដើម្បីលើកតម្កើងអក្សរសាស្ត្រ និង វប្បធម៌ខ្មែរ ។ សម្តេចព្រះសង្ឃរាជអង្គនេះ ទ្រង់បាននិពន្ធសៀវភៅវចនានុក្រមខ្មែរ និង សៀវភៅមួយចំនួនទៀតសំរាប់ការសិក្សារបស់ព្រះសង្ឃ និង ពុទ្ធបរិស័ទទាំងឡាយ ។ សម្តេច ជួន ណាតចេះភាសាបារាំង អង់គ្លេស ថៃ ឡាវ ភូមា វៀតណាម និង ចិនខ្លះៗ ។ សម្តេចបង្រៀនភាសាបាលី និង សំស្ក្រឹត ព្រមទាំងផ្តល់បទសំភាសន៏ផ្នែកអក្សរសាស្ត្ររៀងរាល់សប្តាហ៍ តាមវិទ្យុជាតិ ។ កម្មវិធីសំភាសន៍អក្សរសាស្ត្រនេះ មានប្រជាប្រិយភាពខ្លាំងណាស់ ហើយខ្ញុំក៏តែងតែត្រងត្រាប់ស្តាប់ពុំដែលខានឡើយ។ សម្តេចព្រះសង្ឃរាជមានសិស្សានុសិស្សរបស់លោកជាច្រើន ដែលជាមន្ត្រីរាជការ ដែលមានអ្នកខ្លះបានក្លាយទៅជារដ្ឋមន្ត្រី ឬ មន្ត្រីជាន់ខ្ពស់ក្នុងជួររាជរដ្ឋាភិបាលផង ។ តាមក្បួនពិធីការនៃព្រះបរមរាជវាំង សម្តេចព្រះសង្ឃរាជមានឋានៈស្មើនឹងស្តេចផែនដីមួយអង្គដែរ ដែលគេត្រូវប្រើពាក្យរាជសព្ទដើម្បីថ្លែងទៅកាន់ព្រះអង្គ ។

សូមបញ្ជាក់ថា បើប្រៀបធៀបទៅភាសាបរទេស ភាសាខ្មែរយើងមានភាពសម្បូណ៌បែបសម្បើមណាស់ ព្រោះខ្មែរយើងមានពាក្យជាច្រើន ដែលមានន័យដូចគ្នា សំរាប់យកទៅប្រើឲ្យសមតាមឋានៈសង្គម ពោលគឺខ្មែរយើងមានពាក្យសំរាប់ប្រើជាមួយស្តេច ជាមួយមន្ត្រី ជាមួយរាស្ត្រ ជាមួយព្រះសង្ឃ ជាមួយគ្រហស្ថ ជាមួយមនុស្សចាស់ និង ជាមួយកូនក្មេងជាដើម ។ គ្រាន់តែពាក្យស៊ី មានមិនតិចជាងដប់ពាក្យទេ ។

សម្តេចព្រះសង្ឃរាជ ជួន ណាត បានសុគតតាំងពីខែ កញ្ញា ១៩៦៩ មកម្ល៉េះ ដូច្នេះបើតាមពិធីការ ព្រះបរមសពរបស់ព្រះអង្គ ត្រូវតំកល់ទុកយ៉ាងហោចណាស់ក្នុងរវាងប្រាំមួយខែ ទើបគេប្រារព្ធព្រះរាជពិធីថ្វាយព្រះភ្លើង ដែលអាចនឹងត្រូវកំណត់នៅខែ មីនា ១៩៧០ ។ ធ្វើយ៉ាងនេះ ដើម្បីទុកឱកាសឲ្យ

ប្រជានុរាស្ត្រ ពុទ្ធបរិស័ទមានឱកាសថ្វាយបង្គំព្រះបរមសព ដែលកំពុងតំកល់ទុកនៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។ ក្នុងរយៈពេលនៃការតំកល់ទុកនេះរហូតដល់ថ្ងៃថ្វាយព្រះភ្លើង គេមានរៀបចំពិធី តាមប្រពៃណីព្រះពុទ្ធសាសនាជាប់រហូតទាំងថ្ងៃទាំងយប់ ។ គណៈប្រតិភូខេត្ត ក្រុង បន្តគ្នាពីទីឆ្ងាយជិត លើកគ្នាមកថ្វាយបង្គំព្រះបរមសព ។ ដើម្បីជាកិត្តិយសថ្វាយសម្តេចព្រះសង្ឃរាជ មន្ត្រី ប៉ូលីស ទាហាន និង ក្រុមយុវ័ន ក្នុងសំលៀកបំពាក់ឯកសណ្ឋាន បានត្រូវចាត់ឲ្យទៅឈរយាម ឬធ្វើជារបងកិត្តិយសសំរាប់ទទួលភ្ញៀវជាន់ខ្ពស់ ឬ គណៈប្រតិភូទាំងនោះ ។

# ព្រឹត្តិការណ៍ ១៨ មីនា ១៩៧០

អស់រយៈពេលជាច្រើនខែមកហើយ ដែលខ្ញុំត្រូវបានចាត់តាំងឲ្យមកឈរយាមនៅមាត់ទ្វារព្រះមហាកុដិក្នុងសំលៀកបំពាក់យុវ័ន ។ ជារៀងរាល់ថ្ងៃ នៅពេលទៅដល់ ខ្ញុំតែងតែឈរផតកំរើកនៅនឹងមួយកន្លែង ចាប់ពីម៉ោងបីល្ងាចរហូតដល់ម៉ោងប្រាំបីយប់ ។ កាលសម័យនោះ ខ្ញុំនៅធ្វើការក្នុងក្រុមហ៊ុនរដ្ឋសុរាគារខ្មែរ ។ ខ្ញុំ និង មន្ត្រីថ្នាក់ទាបមួយចំនួន ត្រូវចាត់ឲ្យឈរយាមនៅមហាកុដិនៃសម្តេចព្រះសង្ឃរាជ ។ ពេលនោះ ខ្ញុំពុំបានដឹងថា ពិធីរៀបចំថ្វាយព្រះភ្លើងនឹងត្រូវប្រព្រឹត្តទៅនៅពេលណានោះទេ ខ្ញុំគ្រាន់តែនឹកស្រមៃថា នៅពេលនោះគេនឹងមានប្រារព្ធពិធីដ៏ធំអធិកអធម ដើម្បីឲ្យសមនឹងព្រះឋានៈសម្តេចព្រះសង្ឃរាជ ។ ក៏ប៉ុន្តែ នៅពេលនោះ ប្រជាជាតិយើងកំពុងតែរង់ចាំព្រះរាជដំណើរយាងត្រឡប់មកវិញនៃព្រះប្រមុខរដ្ឋ សម្តេច សីហនុ ដែលទ្រង់បានយាងទៅព្យាបាលព្រះរោគ នៅឯទីក្រុងប៉ារីស ប្រទេសបារាំងអស់រយៈពេលជាច្រើនខែមកហើយ ។ តាមពាក្យចចាមអារាមពីមាត់មួយទៅមាត់មួយថា សម្តេចនឹងទ្រង់យាងមកវិញនៅពាក់កណ្តាលខែ មីនា នេះ ។

នៅក្នុងរយៈពេលអវត្តមានសម្តេចព្រះប្រមុខរដ្ឋ ស្ថានភាពនយោបាយរបស់ប្រទេសយើង ក៏កាន់តែធ្លាក់ចុះដុនដាបទៅជាលំដាប់ ។ ជាច្រើនសប្តាហ៍ និង ជាច្រើនខែមកហើយ សារព័ត៌មានក្នុងស្រុក ដែលជាទម្លាប់សុទ្ធតែមានស្វាមីភក្តិចំពោះសម្តេច បានផ្សព្វផ្សាយព័ត៌មានដ៏អាស្រូវជាច្រើន ទាក់ទងទៅនឹងអំពើពុករលួយរបស់អ្នកនៅជិតនឹងសម្តេចព្រះប្រមុខរដ្ឋ ។ ម្យ៉ាងទៀត ក៏មានការប៉ះទង្គិចខាងផ្លូវអាវុធជាញឹកញាប់រវាងកងយោធពលខេមរភូមិន្ទ និង ពួកវៀតកុងនៅតាមទល់ដែន ។ នៅតាមតុកាហ្វេ អ្នកស្រុកនិយាយយ៉ាងពេញមាត់ថា មានអ្នកធំៗលួចជួយពួកវៀតកុង ដោយបានផ្តល់ដល់ពួកយួនកុម្មុយនីស្តទាំងនេះ នូវស្បៀងអាហារ និងថ្នាំសង្កូវជាដើម ។

នៅថ្ងៃទី ៨ មីនា ១៩៧០ ប្រជាពលរដ្ឋនាំគ្នាធ្វើបាតុកម្មប្រឆាំងនឹងវៀតកុងនៅក្នុងភូមិមួយឈ្មោះ ភូមិចន្ទ្រា នៅខេត្តស្វាយរៀង ។ ពួកអ្នកស្រុកទាំងនោះធ្វើបាតុកម្មទាមទារបណ្តេញពួកវៀតកុងឲ្យចេញពីដីខ្មែរ ។ នៅថ្ងៃ ១១ មីនា ១៩៧០ នៅទីក្រុងភ្នំពេញ និស្សិតក៏នាំគ្នាធ្វើបាតុកម្ម ដែលបានប្រែក្លាយទៅជាអំពើហឹង្សាប្រឆាំងនឹងស្ថានទូតវៀតណាមខាងជើង និង វៀតកុងដោយក្រុមបាតុករនាំគ្នាវាយលុកចូលទៅក្នុងអាគារ ធ្វើឲ្យស្ថានទូតទាំងពីរមានការខូចខាតយ៉ាងដំណំ ។ ចំពោះអ្នកស្រុកធម្មតា គេមិននឹកស្មានថាចាប់ផ្តើមពីបាតុកម្មបែបនេះ សភាពការណ៍ អាចនាំទៅដល់ការទំលាក់សម្តេចព្រះប្រមុខរដ្ឋជាទីគោរពរបស់ពួកគេឲ្យចេញពីអំណាចនោះឡើយ ។ នៅថ្ងៃទី ១៦ មីនា ពួកនិស្សិតបានបន្តធ្វើបាតុកម្មមួយទៀតដែលនៅពេលនោះ បុរសម្នាក់ត្រូវបានក្រុមបាតុករវាយធ្វើបាបយ៉ាងខ្លាំង ព្រោះតែគាត់ហ៊ានស្រែកជេរសម្តេចឪ ។ ក្រុមបាតុករចោទប្រកាន់បុរសនោះថាធ្វើវិទ្ធង្សនា និង ក្បត់ប្រឆាំងនឹងព្រះរាជបល្ល័ង្ក ។ ជាទូទៅ អ្នកស្រុកយល់ថាបាតុកម្មថ្ងៃទី១៦ មីនានោះ ជាបាតុកម្មគាំទ្រសម្តេចឪ មិននឹកស្មានថាបាតុកម្មនោះ

ជាបឋមសញ្ញានៃការផ្លាស់ប្តូរអ្នកដឹកនាំនោះឡើយ ។ មានពាក្យចចាមអារាមខ្លះនិយាយថា ពួកបាតុករដែលហ៊ានធ្វើបាតុកម្មប្រឆាំងស្ថានទូតវៀតណាមទាំងពីរនោះ ប្រាកដជាបានទទួលសញ្ញាភ្លើងខៀវពីសម្តេចឪហើយ ព្រោះថានៅសម័យនោះគ្មាននរណាអាចធ្វើសកម្មភាពនយោបាយអ្វី ដោយគ្មានការយល់ព្រមពីព្រះអង្គនោះឡើយ ។ នៅពេលនោះ ខ្ញុំមិនបានចូលរួមធ្វើបាតុកម្មជាមួយពួកនិស្សិតទេ ព្រោះជាប់បំពេញការងារនៅឯក្រុមហ៊ុនសុរាគារខ្មែរ ។ នៅទីបំផុត អ្វីៗដែលយើងស្មានមិនដល់នោះ ក៏បានកើតឡើងមែន ។ នោះក៏ជាសោកជនាដកម្មដ៏យូរអង្វែងមួយសំរាប់ប្រជាជាតិយើង ។

រសៀលថ្ងៃទី ១៨ មីនា ១៩៧០ នោះគឺ ជាពេលវេលាដ៏ខ្លោចផ្សានៅក្នុងប្រវត្តិសាស្ត្រខ្មែរ ។ នៅពេលនោះ ខ្ញុំកំពុងតែដើរតាមផ្លូវដីដ៏មានធូលីហុយទ្រលោមចេញពីផ្ទះឆ្ពោះទៅផ្សារដើមគក្រោមកំដៅថ្ងៃដ៏ខ្លាំង និង ទៅកាន់ស្ថានីយឡាំប្រឺតា ឬ រថយន្តកង់បី ដើម្បីបន្តដំណើរទៅវត្តឧណ្ណាលោមដូចធម្មតា ។ នៅពេលដើរទៅជិតស្ពានហៀបនឹងឆ្លងទៅស្ថានីយរថយន្តកង់បីនោះ ខ្ញុំឮសម្លេងបទភ្លេងដែលបន្លឺតាមវិទ្យុ នៅតាមតូបលក់ទំនិញទាំងឡាយ ដែលតាំងនៅហូរហែតាមដងផ្លូវគឺសម្លេងបទភ្លេងនគររាជ លាយឡំនឹងសម្លេងទ្រហឹងអឹងអាប់នៃរថយន្ត ឬទោចក្រយានយន្ត ដែលបើកគគ្រឹកគគ្រេង ដោយមានបញ្ចេញសម្លេងស៊ីផ្លេចេញពីច្រើនទិសទៀតផង ។ ក៏ប៉ុន្តែ ខ្ញុំស្តាប់ឮតែវគ្គចុងក្រោយនៃបទនគររាជ ។ ខ្ញុំខំផ្ទៀងត្រចៀកស្តាប់ ដោយនឹកថា ប្រហែលជាវិទ្យុបានផ្សាយនូវព្រះរាជសាររបស់សម្តេចព្រះមហាក្សត្រីយានី[30] ព្រោះតាមធម្មតា បន្ទាប់ពីព្រះអង្គមានព្រះសុវណ្ណីយ៍រួចហើយ វិទ្យុជាតិតែងតែចាក់ផ្សាយនូវបទនគររាជជាកិត្តិយស ។ ក៏ប៉ុន្តែនៅលើកនេះ បន្ទាប់ពីសម្លេងបទភ្លេងនគររាជ ខ្ញុំឮតែសម្លេងភ្លេងព្យុហយាត្រា

---

[30] សម្តេចព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ កុសុមៈ ជាព្រះមាតារបស់សម្តេច សីហនុ ។

(Marche militaire) នៃក្រុមយោធា ដែលមានលក្ខណៈខុសប្លែកពីធម្មតា ។ នៅក្នុងតូបលក់ទំនិញនីមួយៗ ខ្ញុំឃើញមនុស្សម្នាអង្គុយជុំៗស្តាប់វិទ្យុផ្សាយសម្លេង ។ ពួកគេហាក់ដូចកំពុងតាមដានព្រឹត្តិការណ៍ដ៏សំខាន់អ្វីមួយ ។ ខ្ញុំក៏បង្អន់ល្បឿនរង់ចាំស្តាប់វិទ្យុដូចគេដែរ ។ មិនយូរប៉ុន្មាន បទភ្លេងយោធាព្យុហយាត្រាក៏ត្រូវផ្អាក ហើយវិទ្យុជាតិ ក៏ចាក់ផ្សាយនូវសេចក្តីប្រកាសព័ត៌មានរបស់លោក ចេង ហេង ប្រធានរដ្ឋសភា ដែលកំពុងកាន់តំណែងជាប្រមុខរដ្ឋស្តីទីក្នុងពេលអវត្តមានសម្តេចសីហនុ ។ លោក ចេង ហេង មានប្រសាសន៍ ក្នុងសារដ៏ខ្លីរបស់គាត់មានន័យជាអាទិថា "រដ្ឋសភា និង ក្រុមប្រឹក្សាព្រះរាជាណាចក្រ ដែលបានរួមប្រជុំជាសមាជបានសំរេចដកសេចក្តីទុកចិត្តពីសម្តេច នរោត្តម សីហនុ ពីតំណែងរបស់ព្រះអង្គចាប់ពីម៉ោងដប់បីនៃថ្ងៃទី ១៨ មីនា ១៩៧០ នេះតទៅ"[31] ។ ព័ត៌មាននេះបានធ្វើឲ្យខ្ញុំភាំងស្មារតី ដូចត្រូវធក់នឹងចរន្តអគ្គិសនី ហើយខ្ញុំក៏ប្រញាប់ប្រញាល់ត្រឡប់ទៅផ្ទះវិញ លះបង់ចោលនូវគំនិតដើម ដែលថានឹងទៅបំពេញករណីយកិច្ចយាមព្រះមហាកុដិថ្វាយសម្តេចព្រះសង្ឃរាជដូចសព្វៗដង ។

ពេលមកដល់ផ្ទះ ខ្ញុំឃើញបងប្រុសខ្ញុំទាំងពីរនាក់កំពុងអង្គុយស្តាប់វិទ្យុយ៉ាងយកចិត្តទុកដាក់ ។ អ្នកទាំងពីរក៏យល់ស្របតាមខ្ញុំគឺ មិនគួរចេញទៅក្រៅផ្ទះទេថ្ងៃនេះ ហើយយើងគួរតែត្រៀមលក្ខណៈ ចំពោះហេតុការណ៍ដ៏អាក្រក់ទាំងឡាយដែលអាចនឹងកើតមានឡើង ។ យើងបញ្ឈប់សកម្មភាពអ្វីផ្សេងៗទាំងអស់ ហើយយើងទាំងបីនាក់បន្តស្តាប់វិទ្យុតទៅទៀត ។ នៅពេលនោះខ្ញុំមានអារម្មណ៍ថា ព្រឹត្តិការណ៍នេះអាចមានការពាក់ព័ន្ធសាំញ៉ាំ នាំទៅបង្កឲ្យមានសង្គ្រាមលោកលើកទីបីផង ។

---

[31] Ministère de l 'Information, Documents, Cabinets Ministériels Khmers, du 18 mars 1945 au 18 mars 1970, Message à la Nation de Son Excellence Cheng Heng, Président de l'Assemblée Nationale, Exerçant les Pouvoirs de Chef de l'Etat, op. cit, p. 120.

ផ្ទុយទៅវិញ បងប្រុសទីពីររបស់ខ្ញុំប្រកាន់ឥរិយាបថដូចគ្នានឹងក្រុមនិស្សិតសាកលវិទ្យាល័យទាំងឡាយដែលមានសុទិដ្ឋិនិយម និង គាំទ្រការទំលាក់សម្តេច សីហនុ ។ ពួកនិស្សិតជំនាន់នោះមានការពេញចិត្តចំពោះការដួលរលំនៃរបបរាជានិយម ។ បងប្រុសខ្ញុំមានជំនឿថា ព្រឹត្តិការណ៍នេះ ជាព្រឹត្តិការណ៍ដ៏សំខាន់ដែលនាំមកប្រទេសកម្ពុជាយើងនូវលទ្ធិប្រជាធិបតេយ្យយ៉ាងពិតប្រាកដ ។

វិទ្យុជាតិនៅបន្តផ្សាយបទភ្លេងយោធាព្យុហយាត្រា លាយឡំនឹងសារលោកប្រមុខរដ្ឋស្តីទីព្រមជាមួយនិងសេចក្តីប្រកាសព័ត៌មានរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលចុងក្រោយសម័យនោះមានឈ្មោះថា "រដ្ឋាភិបាលស្រោចស្រង់ជាតិ" ។ កាលនោះ សម្តេច សីហនុ បានតែងតាំងរដ្ឋាភិបាលមួយក្រោមការដឹកនាំរបស់លោក លន់ នល់ ជានាយករដ្ឋមន្ត្រី នៅចុងខែ មករា ១៩៦៨ ។ ក្នុងជំនាន់សម្តេច សីហនុ កាន់អំណាចនោះ រាជរដ្ឋាភិបាលត្រូវបានផ្លាស់ប្តូរជាញឹកញាប់តាមព្រះទ័យរបស់ព្រះអង្គ ។ រាជរដ្ឋាភិបាលនីមួយៗ ជាទូទៅមានអាយុមិនលើសពីប្រាំមួយខែឡើយ ។ នៅក្នុងការផ្សាយរបស់វិទ្យុជាតិនោះ យើងឮសេចក្តីជូនដំណឹងធ្វើឡើងដោយលោកឧត្តមសេនីយ លន់ នល់ ដែលជំរាបជូនសាធារណជនអំពីការដកហូតមុខតំណែងស្នងការកណ្តាលប៉ូលីស ប្រចាំរាជធានីភ្នំពេញ ដែលជាមនុស្សជំនិតម្នាក់របស់សម្តេច នរោត្តម សីហនុ ។ តាមការផ្សាយដំណឹងផ្សេងទៀត លោកឧត្តមសេនីយ លន់ នល់ បានចុះហត្ថលេខាលើសេចក្តីប្រកាសព័ត៌មានរបស់រដ្ឋាភិបាលស្រោចស្រង់ជាតិស្តីពីវិបត្តិនយោបាយដែលគេចោទថា បង្កើតឡើងដោយសម្តេច សីហនុ និង ស្តីពីសេចក្តីសម្រេចរបស់រដ្ឋសភា និង ក្រុមប្រឹក្សាព្រះរាជាណាចក្រក្នុងការដកហូតតំណែងប្រមុខរដ្ឋពីសម្តេច នរោត្តម សីហនុ ដែលត្រូវជំនួសដោយលោក ចេង ហេង រហូតដល់ពេលមានការបោះឆ្នោតរើសប្រមុខរដ្ឋថ្មី

ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា[32] ។ ពួកយើងទាំងបីនាក់បន្តចំណាយពេលស្តាប់វិទ្យុរហូតដល់ពេលយប់ជ្រៅ ។ នៅទីបំផុត វិទ្យុជាតិក៏បានធ្វើការចាក់ផ្សាយនូវការពិភាក្សារបស់រដ្ឋសភា ស្តីអំពីការសំរេចចិត្តដកតំណែងប្រមុខរដ្ឋពីសម្តេច សីហនុ ។

សមាជិកសភា និង ក្រុមប្រឹក្សាព្រះរាជាណាចក្រ បានលើកយកការអនុវត្តរដ្ឋធម្មនុញ្ញមកជជែកដោយមិនបាននិយាយអំពីរដ្ឋប្រហារយោធាណាមួយឡើយ ។ វាគ្មិនជាច្រើនដែលគេស្គាល់ថាធ្លាប់មានភក្តីភាពចំពោះសម្តេចព្រះប្រមុខរដ្ឋ បានធ្វើការវាយប្រហារយ៉ាងខ្លាំងទៅលើព្រះអង្គ ។ លោក អ៊ិន តាំ ដែលជាប្រធានរដ្ឋសភាស្តីទី បានចេញមុខប្រឆាំងនឹងសម្តេចយ៉ាងខ្លាំងក្លា ។ នៅក្នុងសម័យប្រជុំនោះ ពួកអ្នកតំណាងរាស្ត្រ និង ក្រុមសមាជិកក្រុមប្រឹក្សាព្រះរាជាណាចក្រ បានចោទប្រកាន់សម្តេច សីហនុ លើបទល្មើសប្រាំប្រការគឺ៖[33] អំពើក្បត់ជាតិ ការរំលោភជាញឹកញាប់លើរដ្ឋធម្មនុញ្ញ ការលួចសម្បត្តិជាតិ អំពើពុករលួយ និង ការធ្វើឲ្យបាត់បង់នូវសេចក្តីថ្លៃថ្នូរ និង កិត្តិយសជាតិ ។ ក្នុងឋានៈជាពលរដ្ឋតូចតាច ពួកយើងពុំបានយល់ស៊ីជម្រៅនូវអ្វីដែលហៅថានយោបាយឡើយ ។ ក៏ប៉ុន្តែ បើគ្រាន់តែស្តាប់ការពិភាក្សាតាមផ្លូវច្បាប់អំពីវិធីជ្រើសរើស និង ការតែងតាំងប្រមុខរដ្ឋអាចធ្វើឲ្យយើងជឿបានថានោះគឺ ជាការអនុវត្តតាមរដ្ឋធម្មនុញ្ញ មិនមែនជារដ្ឋប្រហារយោធាណាមួយឡើយ ។

[32] Ministère de l 'Information, Documents, Cabinets Ministériels Khmers, du 18 mars 1945 au 18 mars 1970, "Communiqué du Gouvernement de Sauvetage", op. cit, p. 119.

[33] Ministère de l 'Information, Documents, Cabinets Ministériels Khmers, du 18 mars 1945 au 18 mars 1970, "Motion à l'Assemblée Nationale", op. cit, pp. 126-127.

# គេថាធ្វើតាមរដ្ឋធម្មនុញ្ញ[34]

ច្បាប់រដ្ឋធម្មនុញ្ញទីមួយនៃព្រះរាជាណាចក្រកម្ពុជា បានត្រូវប្រកាសឲ្យប្រើនៅខែ ឧសភា ១៩៤៧ នៅពេលដែលសម្ដេច នរោត្តម សីហនុ ទ្រង់សោយរាជ្យនៅឡើយ ។ សូមរំលឹកថា នៅឆ្នាំ ១៩៤១ អាជ្ញាធរអាណាព្យាបាលបារាំងបានជ្រើសរើសសម្ដេច សីហនុ ឲ្យគ្រងរាជសម្បត្តិជំនួសព្រះអយ្យកោ ( ជីតា ) របស់ព្រះអង្គគឺ ព្រះករុណាព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ក្រោយពេលទ្រង់បានសោយព្រះទីវង្គតទៅ ។ ដូច្នេះនៅក្នុងព្រះជន្មតែ ១៩ ព្រះវស្សា សម្ដេច សីហនុ ឡើងគ្រងរាជសម្បត្តិជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ នៅឆ្នាំ ១៩៥៥ ព្រះករុណាព្រះបាទសម្ដេច នរោត្តម សីហនុ បានទ្រង់ដាក់រាជ្យថ្វាយព្រះបិតារបស់ព្រះអង្គគឺព្រះករុណាព្រះបាទ សុរាម្រឹត ដើម្បីមានឱកាសចូលប្រឡូកក្នុងឆាកនយោបាយ ។ នេះជាករណីមួយដ៏ចំឡែក នៅក្នុងប្រទេសកម្ពុជាយើង ។ តាមធម្មតាគេធ្លាប់តែឃើញ ព្រះបិតា "ឪពុក" បង្វែររាជសម្បត្តិទុកឲ្យព្រះរាជបុត្រ "កូន" តែក្នុងករណីសម្ដេច សីហនុ នេះគឺ ព្រះអង្គជាបុត្រផ្ទេរ រាជសម្បត្តិថ្វាយព្រះរាជបិតាព្រះអង្គទៅវិញ ។

នៅសម័យនោះ ប្រទេសកម្ពុជាប្រកាន់របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ (Monarchie constitutionnelle) ដែលមានព្រះមហាក្សត្រជាប្រមុខរដ្ឋ ។ ចាប់ពីទ្រង់ដាក់រាជសម្បត្តិមក សម្ដេច សីហនុ បានបំពេញមុខនាទីជានាយករដ្ឋមន្ត្រី ជាច្រើនលើកច្រើនសារ ។ ក៏ប៉ុន្តែ ក្នុងសម័យមុនឆ្នាំ ១៩៧០ នោះនាយករដ្ឋមន្ត្រីអាចប្រគល់នាទីឲ្យរដ្ឋមន្ត្រីទី១ ធ្វើការជំនួសក៏បាន ។ ឧទាហរណ៍

[34] ទាំងប្រកាសព័ត៌មានរបស់រដ្ឋាភិបាលស្រោចស្រង់ជាតិ ទាំងសារជូនប្រជាជាតិរបស់លោក ចេង ហេង ប្រមុខរដ្ឋស្តីទី សុទ្ធតែបានចែងថាការដកសម្ដេច សីហនុ ពីតំណែងប្រមុខរដ្ឋ ធ្វើឡើងតាមរដ្ឋធម្មនុញ្ញទាំងអស់ ។

ដូចជានៅឆ្នាំ ១៩៦៨ ដោយសារសម្តេច សីហនុ ទ្រង់កាន់តំណែងជាប្រមុខរដ្ឋផង ជានាយករដ្ឋមន្ត្រីផង ទើបព្រះអង្គបានតែងតាំងលោក សឺន សាន ជារដ្ឋមន្ត្រីទី១ ឲ្យដឹកនាំការងាររាជរដ្ឋាភិបាលជំនួសព្រះអង្គ ។

នៅឆ្នាំ ១៩៦០ នៅពេលដែលព្រះករុណាព្រះបាទ សុរាម្រឹត បានទ្រង់ចូលទីវង្គត សម្តេច សីហនុ បានធ្វើឲ្យមានការកែប្រែរដ្ឋធម្មនុញ្ញ ដើម្បីបង្កើតឲ្យមានមុខតំណែងព្រះប្រមុខរដ្ឋមួយឡើង ។ នៅពេលនោះ ព្រះអង្គទ្រង់ទទួលយកតំណែងជាព្រះប្រមុខរដ្ឋនេះ ដោយរក្សាទុកព្រះវរមាតាជាសម្តេចព្រះមហាក្សត្រីយានី ដែលជានិមិត្តរូបនៃព្រះរាជបល្ល័ង្ក ។ តាមការកែសំរួលថ្មីនៃរដ្ឋធម្មនុញ្ញនោះ មុខតំណែងប្រមុខរដ្ឋ ត្រូវជ្រើសរើសឡើងដោយចលនាសង្គមរាស្ត្រនិយមហើយនិងទទួលបានការបោះឆ្នោតគាំទ្រដោយអង្គប្រជុំពិសេសរបស់រដ្ឋសភា និង ក្រុមប្រឹក្សាព្រះរាជាណាចក្រ ដែលហៅថាអង្គប្រជុំសមាជ ។ នៅថ្ងៃ ១៨ មីនា ១៩៧០ នេះ ក៏មានការប្រជុំជាសមាជ ដើម្បីដកហូតសេចក្តីទុកចិត្តពីសម្តេច សីហនុ ក្នុងតំណែងព្រះអង្គជាប្រមុខរដ្ឋដែរ ។ ក៏ប៉ុន្តែ នៅពេលនោះ រដ្ឋសភា និង ក្រុមប្រឹក្សាព្រះរាជាណាចក្រ ពុំបានជ្រើសរើសបេក្ខជនណាមួយឲ្យមកកាន់តំណែងប្រមុខរដ្ឋជំនួសព្រះអង្គឡើយ ។

យប់ទីមួយនៃទិវាដ៏ខ្មៅងងឹតក្នុងប្រវត្តិសាស្ត្រនេះ មានសភាពស្ងប់ស្ងៀមល្អណាស់ ក៏ប៉ុន្តែពួកយើង មិនបានទទួលទានដំណេកឲ្យបានលង់លក់ដូចធម្មតាឡើយ ។ ព្រឹកឡើងយើងនាំគ្នាទៅធ្វើការតាមទំលាប់ ។ នៅតាមផ្លូវ ខ្ញុំសង្កេតឃើញចលនាឥតឈប់ឈរនៃរថយន្តយោធា ពីផ្លូវមួយទៅផ្លូវមួយ ពីទីកន្លែងមួយ ទៅទីកន្លែងមួយ ។ យោធាដែលមានប្រដាប់ដោយអាវុធយ៉ាងសម្បើមផងនោះ បាននាំខ្លួនមន្ត្រីជាន់ខ្ពស់នៃរបបសម្តេច សីហនុ ដឹកឆ្ពោះទៅទីកន្លែងដែលយើងមិនស្គាល់ ។ ខ្ញុំឮគេនិយាយថា មន្ត្រីជាន់ខ្ពស់ទាំងនោះត្រូវបាននាំយកទៅឃុំខ្លួន ។

ខ្ញុំសង្កេតឃើញមានរទេះតង់ និង រថពាសដែកមួយចំនួននៅខាងមុខអាគារសាធារណៈ ឬ អាគាររបស់រដ្ឋាភិបាល ។ ចរាចរណ៍តាមផ្លូវហាក់ដូចជាប្រព្រឹត្តទៅដោយស្រួល និង មានរបៀបរៀបរយជាងមុន ។ ខ្ញុំសង្កេតឃើញថាក្នុងរយៈពេលមួយខែបន្ទាប់ពីព្រឹត្តិការណ៍ ១៨ មីនា នោះ ការអនុវត្តច្បាប់ និង ការគោរពច្បាប់ហាក់ដូចជាបានប្រព្រឹត្តទៅយ៉ាងត្រឹមត្រូវ និង ហ្មត់ចត់ជាទីបំផុត ។

## រដ្ឋាភិបាល លន់ នល់ កំចាត់វៀតណាមកុម្មុយនីស្ត

របបថ្មីដែលទើបតែងតាំងឡើងនេះបានផ្អែកធម្មានុរូបភាព[35] (Légitimité) របស់ខ្លួន ទៅលើមនោសញ្ចេតនាស្អប់យួនរបស់ខ្មែរភាគច្រើននៅពេលនោះ ។ ខ្មែរយើងមួយចំនួនយល់ថាជនជាតិវៀតណាមជាសត្រូវស្នូពូជ ។ ប្រទេសកម្ពុជាយើងបានត្រូវបាត់បង់ទឹកដីមួយចំនួន ដោយសារជនជាតិវៀតណាមជាច្រើនសតវត្សកន្លងមកហើយ ។ ដូច្នេះគេមិនអាចឲ្យមានការបាត់បង់ទឹកដីខ្មែរតទៅទៀតបានឡើយ ។ ការកាន់កាប់ទឹកដីណាមួយរបស់ខ្មែរដោយជនជាតិវៀតណាម អាចដុតភ្លើងកំហឹងរបស់ជនជាតិខ្មែរ ដែលភាគច្រើនជាអ្នកជាតិនិយមឆ្អិនឆ្អៅ ។ នៅពេលនោះ យើងមិនបាននឹកដល់សង្គ្រាមស៊ីវិលរវាងខ្មែរ និង ខ្មែរនោះទេ ព្រោះខ្មែរណាក៏ដូចខ្មែរណា ជឿថាគេមិនអាចសំលាប់ខ្មែរគ្នាឯងបានឡើយ ។ ប្រសិនបើមានបរទេសឈ្លានពាន ប៉ុនប៉ងដណ្តើមទឹកដីខ្មែរ ខ្មែរម្នាក់ៗត្រៀមខ្លួនជាស្រេច ដើម្បីធ្វើពលីកម្ម ចំពោះជាតិមាតុប្រទេស ។ ខ្ញុំជឿថារហូតមកដល់ថ្ងៃនេះ ខ្មែរយើងភាគច្រើន នៅតែមានសេចក្តីស្នេហាជាតិបែបនេះជានិច្ច ។

រដ្ឋាភិបាល លន់ នល់ បានធ្វើការឃោសនាយ៉ាងខ្លាំងក្លា និង កាចសាហាវ

[35] អាចនិយាយពីលក្ខណៈស្របច្បាប់ ឬ ដែលមិនផ្ទុយពីច្បាប់ក៏បាន ។

ប្រឆាំងវៀតណាមកុម្មុយនីស្តគឺ ពួកវៀតកុង និង វៀតណាមខាងជើង ដោយគេប្រកាន់គោលជំហរថាការទំលាក់សម្តេច សីហនុ ចេញពីតំណែងនោះគឺ ជាកិច្ចប្រតិបត្តិការជៀសមិនរួច ដើម្បីបញ្ឈប់ការកាន់កាប់ទឹកដីខ្មែរដោយពួកវៀតណាមកុម្មុយនីស្តទាំងនោះ ។

សូមបញ្ជាក់ថានៅសម័យនោះ ពួកវៀតកុង( Viet Cong)[36] និង វៀតណាមខាងជើង បានទទួលការគាំទ្រយ៉ាងរឹងមាំពីអាណិកជនវៀតណាមនៅកម្ពុជា និងពីសម្តេច សីហនុ ។ លោក លន់ នល់ ក៏បានចាប់ផ្តើមបំផ្លាញចោលនូវរាល់បណ្តាញវៀតណាមនៅក្នុងប្រទេស ។ ដំណាក់កាលដំបូង មានការចាប់ឃាត់ជនសង្ស័យថាជាបណ្តាញវៀតណាមកុម្មុយនីស្ត ហើយបន្តបន្ទាប់មក ក៏ចាប់ផ្តើមបណ្តេញជនជាតិវៀតណាមជាទូទៅចេញពីកម្ពុជា។ ជនជាតិវៀតណាមទាំងនោះត្រូវចាត់ឲ្យទៅនៅក្នុងជំរុំបណ្តោះអាសន្ន មុននឹងត្រូវគេបញ្ជូនទៅប្រទេសគេវិញ ឬទៅប្រទេសទី៣ ។

នៅពេលនោះ មានជនជាតិវៀតណាមជាច្រើន ប្រញាប់ប្រញាល់លក់ចេញនូវទ្រព្យសម្បត្តិរបស់ខ្លួន ឬ ឧបករណ៍ប្រើប្រាស់ល្អៗទាំងឡាយ រួចស្ម័គ្រចិត្តចូលទៅរស់នៅក្នុងជំរុំតាមការកំណត់របស់រដ្ឋាភិបាល ជាជាងរង់ចាំឲ្យប៉ូលីសចូលមកចាប់ខ្លួន ។ នៅក្នុងសភាពការណ៍បែបនេះ ខ្ញុំក៏ឆ្លៀតទិញបាននូវវិទ្យុមួយគ្រឿងដែលមានតំលៃថោកសមល្មម ហើយដែលអាចឲ្យខ្ញុំចាប់បាននូវការផ្សាយព័ត៌មាន

[36] មុនឆ្នាំ ១៩៧៥ ប្រទេសវៀតណាមចែកជាពីរគឺ ប្រទេសវៀតណាមខាងជើង ដែលជាប្រទេសសង្គមនិយម និង ប្រទេសវៀតណាមខាងត្បូងដែលជាប្រទេសសេរី និង ជាសម្ព័ន្ធមិត្តរបស់ស.រ.អា ។ ប្រទេសទាំងពីរធ្វើសង្គ្រាមរវាងគ្នានិងគ្នាដោយប្រទេសវៀតណាមខាងជើង ជួយពួកវៀតកុងឲ្យផ្តួលរំលំរបបសេរី នៅវៀតណាមខាងត្បូង ។ ពួកវៀតកុងជាយុទ្ធជនបដិវត្តនៅវៀតណាមខាងត្បូង បានបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នមួយ ដែលរាជរដ្ឋាភិបាលរបស់សម្តេច សីហនុ ទទួលស្គាល់ថាជា រដ្ឋាភិបាលស្របច្បាប់ ។ ក្រោយជ័យជំនះឆ្នាំ ១៩៧៥ ប្រទេសវៀតណាមទាំងពីរបានបញ្ចូលគ្នាជាប្រទេសតែមួយវិញឈ្មោះថា សាធារណរដ្ឋសង្គមនិយមវៀតណាមរហូតសព្វថ្ងៃ ។

អន្តរជាតិពីប្រទេសផ្សេងៗ ។ នយោបាយរបស់រដ្ឋាភិបាល លន់ នល់ ប្រឆាំងវៀតណាម បានទទួលការគាំទ្រយ៉ាងខ្លាំងពីក្រុមនិស្សិត បញ្ញវន្ត និង អ្នករស់នៅក្នុងទីក្រុង ។ យុវជនខ្មែរមួយចំនួន បានស្ម័គ្រចិត្តចូលបំរើកងទ័ព លន់ នល់ ។ យុវជនដែលមានចិត្តពោរពេញទៅដោយសេចក្តីស្នេហាជាតិនោះ ត្រូវបានគេបញ្ជូនទៅសមរភូមិមុខភ្លាមៗ ដោយពុំបានទទួលការរៀបចំ និង ហ្វឹកហាត់ឲ្យបានមាំមួនផ្ទុយស្រឡះពីពួកវៀតកុង ដែលគេស្គាល់ថា ជាយុទ្ធជនមានបទពិសោធន៍យ៉ាងល្បីល្បាញក្នុងពិភពលោក ។ យុវជនទាំងនោះក៏ត្រូវពលីជីវិតភ្លាមៗ នៅទីលានប្រយុទ្ធ ។ យុវជនខ្មែររាប់ពាន់នាក់ បានត្រូវស្លាប់នៅប៉ុន្មានខែដំបូងនៃសង្គ្រាម ដែលគេនឹកថាស្លាប់ដើម្បីបុព្វហេតុជាតិ ។

ផ្ទុយពី បងស៊ីនឿន ដែលសំដែងការគាំទ្រចំពោះរដ្ឋអំណាចថ្មី ខ្ញុំមានគំនិតអភិរក្សជាង ហើយសំដែងការព្រួយបារម្ភពីវាសនារបស់យើងទាំងអស់គ្នា ។ កាលណាយើងជជែកគ្នាអំពីនយោបាយ យើងតែងប៉ះទង្គិចពាក្យសំដីគ្នាជានិច្ច ព្រោះយើងតែងអាងហេតុផលផ្សេងៗពីគ្នា ។ ក៏ប៉ុន្តែជានិច្ចកាលបងទី១ ហៅ បងនាង ឬ បងឈឿន តែងគាំទ្រខ្ញុំ ដូច្នេះនៅក្នុងផ្ទះយើងៗមានគ្នាពីរនាក់ ដែលមានគំនិតដូចគ្នាប្រឆាំងនឹងម្នាក់ទៀត ដែលមានគំនិតគាំទ្ររបបថ្មី ។

ដោយសារវិទ្យុទទួលសម្លេងរបស់ខ្ញុំមានកំលាំងខ្លាំង ខ្ញុំមានការងាយស្រួលក្នុងការបើកស្តាប់ ដោយលួចលាក់នូវការផ្សាយប្រចាំថ្ងៃរបស់វិទ្យុប៉េកាំង ។ នៅពេលនោះ វិទ្យុនេះតែងធ្វើបទអត្ថាធិប្បាយនយោបាយ ដែលទទួលការពេញចិត្តពីប្រជាពលរដ្ឋមួយចំនួនធំ ដែលនៅតែមានស្វាមីភ័ក្តិ គោរព និង ស្រឡាញ់សម្តេចសីហនុ តទៅទៀតនោះ ។

# សម្តេច សីហនុ មានប្រតិកម្មតបវិញ

សម្តេច នរោត្តម សីហនុ បានយាងចេញពីទីក្រុងប៉ារីសឆ្ពោះទៅទីក្រុងមូស្គូ នៅថ្ងៃទី ១៣ មីនា ១៩៧០ ។ ថ្ងៃទី ១៣ តាមធម្មតាចំពោះពួកអ្នកហែរហមព្រះអង្គខ្លះ ដែលជឿលើអបិយជំនឿនិយាយថាមិនគួរនឹងធ្វើដំណើរនៅថ្ងៃនោះឡើយ ។ សម្តេចទ្រង់ត្រូវធ្វើដំណើរទស្សនកិច្ចមួយនៅសហភាពសូវៀត ។ នៅថ្ងៃដែលពួក លន់ នល់ ទំលាក់ព្រះអង្គចេញពីតំណែងនោះ ក៏ត្រូវចំថ្ងៃដែលព្រះអង្គត្រូវយាងចេញពីក្រុងមូស្គូឆ្ពោះទៅប្រទេសចិន ។ អ្នកហែរហមព្រះអង្គមួយចំនួន បានទទួលដំណឹងតាមវិទ្យុរួចហើយ នូវដំណឹងអាក្រក់ស្តីពីការដកហូតតំណែងនោះ ក៏ប៉ុន្តែគ្មាននរណាហ៊ានទៅទូលព្រះអង្គដោយផ្ទាល់ឡើយ ។ នៅក្នុងរថយន្ត ដែលព្រះអង្គគង់ប្រថាប់ជាមួយលោកនាយករដ្ឋមន្ត្រី កូស៊ីហ្គីន តាមក្បួនរថយន្តឆ្ពោះទៅវាលយន្តហោះ គឺលោកនាយករដ្ឋមន្ត្រីសូវៀតនេះហើយ ដែលទូលថ្វាយសម្តេចនូវដំណឹងដ៏អាក្រក់នោះ ។ នៅក្នុងសៀវភៅ ដែលមានចំណងជើងថា "សេ អ៊ី អា ប្រឆាំងប្រទេសកម្ពុជា"[37] ឆ្លើយនឹងសំណួររបស់លោកនាយករដ្ឋមន្ត្រីសូវៀត ដែលចោទសួរព្រះអង្គថា តើព្រះអង្គមានបំណងនឹងធ្វើដូចម្តេចចំពោះហេតុការណ៍នេះ? សម្តេច មានបន្ទូលថា ខ្ញុំនឹងបន្តប្រឆាំងតបតវិញ ។ ប្រតិកម្មរបស់សម្តេចមានលក្ខណៈភ្លាមៗ គឺត្រូវការប្រឆាំងទប់ទល់ និង សងសឹកពួក លន់ នល់ វិញ ។

នៅពេលដែលព្រះអង្គយាងដល់ទីក្រុងប៉េកាំង ព្រះអង្គត្រូវបានទទួលស្វាគមន៍ដោយលោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ នៃប្រទេសចិន ដែលបានអញ្ជើញបណ្តាអង្គទូតប្រចាំប្រទេសចិនទាំងអស់ ឲ្យមកធ្វើបដិសណ្ឋារកិច្ចថ្វាយ

---

[37] Norodom Sihanouk, La C.I.A. Contre le Cambodge, François Maspero, Paris, 1973, p. 13-21.

ព្រះអង្គ ដើម្បីបង្ហាញថា សម្តេចទ្រង់នៅតែត្រូវបានទទួលស្គាល់ជាព្រះប្រមុខរដ្ឋពេញច្បាប់នៃប្រទេសកម្ពុជា ។ នៅក្នុងសៀវភៅនោះ ឆ្លើយតបនឹងសំណួររបស់លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ ដែលចោទសួរដូចលោក កូស៊ីហ្គីន ដែរនោះ សម្តេចទ្រង់មានបន្ទូលថា "ខ្ញុំនឹងធ្វើការតស៊ូរហូតដល់ជីវិតចុងក្រោយ" ។ ក៏ប៉ុន្តែ លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ ទូលសុំឲ្យសម្តេចពិចារណាឲ្យមែនទែនក្នុងរយៈពេលម្ភៃបួនម៉ោងខាងមុខ មុននឹងសំរេចជាចុងក្រោយ ។

មួយថ្ងៃបន្ទាប់មក សម្តេច សីហនុ ក៏បានជួបជាមួយលោកនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង នៃប្រទេសវៀតណាមខាងជើង ដែលបានធ្វើដំណើរពិសេសពីទីក្រុងហាណូយមកទីក្រុងប៉េកាំង ដើម្បីពិភាក្សាអំពីបញ្ហាកម្ពុជា ។ លោក ផាំ វ៉ាន់ដុង បានទូលសួរព្រះអង្គថា តើសម្តេចចង់ឲ្យភាគីវៀតណាម ជួយព្រះអង្គយ៉ាងដូចម្តេច?សម្តេចមានបន្ទូលឆ្លើយតបទៅវិញក្នុងន័យជាអាទិថា៖ "យើងខ្ញុំត្រូវការគ្រូបង្វឹកយោធា ឬ យោធាចារ្យ[38] យើងខ្ញុំមិនខ្វះអ្នកស្ម័គ្រចិត្តកាន់អាវុធទេ ហើយប្រទេសចិនបានសន្យារួចជាស្រេចថា នឹងផ្តល់អាវុធយុទ្ធភណ្ឌ ។ អ្វីដែលយើងខ្វះនោះគឺ កម្មាភិបាលដែលមានការហ្វឹកហាត់គ្រប់គ្រាន់ ។ វៀតណាមមានពួកទាំងនោះ ដ៏ខ្លាំងពូកែមួយក្នុងលោក សម្រាប់ធ្វើសង្គ្រាមប្រភេទនេះ" ។ លោក ផាំ វ៉ាន់ដុង បានឆ្លើយថា "[ទូលបង្គំ]ខ្ញុំនឹងប្រាប់លោក(ឧត្តមសេនីយ) យ៉ាប់[39] ឲ្យបញ្ជូនកម្មាភិបាលពូកែៗចំនួន ២០០០ នាក់ មកថ្វាយព្រះអង្គ" ។ សម្តេច សីហនុ និង លោកនាយករដ្ឋមន្ត្រី ផាំ វ៉ាន់ដុង ក៏បានផ្លាស់ប្តូរមតិគ្នាតទៅទៀតយ៉ាងយូរអំពីមធ្យោបាយល្អៗ ដើម្បីសម្របសម្រួលការតស៊ូប្រយុទ្ធរបស់ប្រជាជនឥណ្ឌូចិន

---

[38] គ្រូបង្វឹកផ្នែកក្បួនយោធា ។

[39] លោកឧត្តមសេនីយ វ៉ូ ង្វៀង យ៉ាប់ ជារដ្ឋមន្ត្រីក្រសួងការពារជាតិនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម នៅសម័យនោះ ។

ទាំងបី ។

នៅថ្ងៃ ២០ និង ២១ មីនា សម្តេចបានប្តេជ្ញាថា នឹងធ្វើការតស៊ូប្រឆាំង លោក លន់ នល់ ហើយនៅថ្ងៃទី ២៣ មីនា ព្រះអង្គក៏ទ្រង់ធ្វើការអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរឲ្យចូលក្នុងព្រៃដែលហៅថា ព្រៃម៉ាគី ដើម្បីរួបរួមគ្នាជាមួយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNK: Gouvernement Royal d'Union Nationale du Kampuchéa) និង រណសិរ្សរួបរួមជាតិកម្ពុជា (FUNK: Front Uni National du Kampuchéa) ដែលនៅពេលនោះ គ្មានអ្នកណាដឹងថាជារដ្ឋាភិបាលស្ថិតនៅក្រោមអំណាចរបស់ពួកខ្មែរក្រហមសោះឡើយ ។ សម្តេច សីហនុ ប្រកាសបង្កើតរាជរដ្ឋាភិបាលក្រៅប្រទេសនេះឡើងជាផ្លូវការនៅថ្ងៃទី ៥ ឧសភា ១៩៧០ ។

ចាប់តាំងពីព្រះអង្គបានមករស់នៅលើទឹកដីនៃប្រទេសចិនមក ទីក្រុងប៉េកាំងបានក្លាយជាបង្អែកដ៏រឹងមាំរបស់ព្រះអង្គ ។ ចំណែកឯវិទ្យុប៉េកាំងវិញក៏បានក្លាយជាឧបករណ៍របស់ព្រះអង្គ ក្នុងការឃោសនាអំពាវនាវប្រកូកប្រកាសឲ្យប្រជាពលរដ្ឋខ្មែរ ក្រោកឡើងប្រឆាំងរបប លន់ នល់ និង ចូលរួមធ្វើបដិវត្តន៍មួយថ្មី ។

## លន់ នល់ ជានរណា ?[40]

មុនថ្ងៃ ១៨ មីនា ១៩៧០ លោក លន់ នល់ បានត្រូវប្រជាពលរដ្ឋទូទៅទទួលស្គាល់ថា ជានាយទាហានមួយរូប ដែលបានទទួលសេចក្តីទុកចិត្តយ៉ាងខ្លាំង

[40] លោក លន់ នល់ បានសរសេរសៀវភៅ **ដំណើរខ្មែរថ្មី (Le néo-khmérisme)** ដើម្បីបង្ហាញអំពីគោលគំនិតនៃរបបរបស់គាត់។

ពីសម្តេចព្រះប្រមុខរដ្ឋ ។ ពួកយើងហៅគាត់ថាលោក General "លោកឧត្តមសេនីយ" ពីព្រោះនៅសម័យនោះលោក លន់ នល់ ជានាយទាហានពាក់ស័ក្តិឧត្តមសេនីយ ដែលគេស្គាល់ជាងគេនៅក្នុងប្រទេស ។ យើងបានដឹងថាលោកឧត្តមសេនីយ លន់ នល់ បានចាប់ផ្តើមពាក់ស័ក្តិប្រាំតែម្តង មិនមែនក្នុងឋានៈជានាយទាហានធម្មតាទេ ។ ដំបូងឡើយ គាត់ធ្វើជាចៅក្រម រួចផ្ទេរក្របខណ្ឌមកជាមន្ត្រីរដ្ឋបាល ធ្វើជាបាឡាត់ស្រុក (មានឋានៈប្រហាក់ប្រហែលអភិបាលរងស្រុក) រហូតឡើងជាចៅហ្វាយខេត្ត ។

នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ នៅពេលដែលព្រះករុណាព្រះបាទ នរោត្តម សីហនុ ទ្រង់បំពេញព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យពីបារាំង លោក លន់ នល់ កំពុងកាន់តំណែងជាចៅហ្វាយខេត្តបាត់ដំបង ។ ដើម្បីដឹកនាំកិច្ចប្រតិបត្តិការសឹកនៅតំបន់នោះ ព្រះមហាក្សត្របានតែងតាំងលោកចៅហ្វាយខេត្ត ក្នុងឋានៈជានាយទាហានស័ក្តិ "វរសេនីយឯក" ។ ដូច្នេះ លោក លន់ នល់ ចាប់ផ្តើមធ្វើទាហានពីស័ក្តិប្រាំ ឡើងរហូតដល់ថ្នាក់ឧត្តមសេនីយឯក ឬ ផ្កាយបី ។

ទោះបីជាលោកមានប្រវត្តិដើម ចេញពីក្របខណ្ឌមន្ត្រីស៊ីវិលយ៉ាងណាក៏ដោយ លោកឧត្តមសេនីយ លន់ នល់ ត្រូវបានទទួលការគោរពយ៉ាងធំធេងពីនាយទាហាន និង ពលទាហានភាគច្រើនរបស់កងទ័ពខ្មែរ ។ ដោយសារគាត់មានសម្បុរខ្មៅ កូនទាហានភាគច្រើនឲ្យឈ្មោះគាត់ថា "ប៉ាខ្មៅ" ។ លោកឧត្តមសេនីយ មានរូបរាងធំខ្ពស់ជាងជនជាតិខ្មែរយើងធម្មតា ដែលគេអាចប្រដូចរូបគាត់ទៅមនុស្សសម័យអង្គរ ។ លោក លន់ នល់ មានដើមកំណើតចេញមកពីខេត្តព្រៃវែងដូចខ្ញុំដែរ ។ ឪពុកគាត់ធ្លាប់ធ្វើជាចៅហ្វាយស្រុក ឯជីតាធ្លាប់ធ្វើជាចៅហ្វាយខេត្ត នៅខេត្តព្រៃវែងនេះតែម្តង ។ លោក លន់ នល់ ជាមនុស្សជឿលើអាគមអូមអាម ដែលតម្រូវ

ឲ្យស្វែងរកគ្រូទាយ ឲ្យគន់គូរកពេលវេលាល្អ ឬ ឲ្យព្រះសង្ឃសូត្រមន្តប្រោះព្រំមុននឹងធ្វើការអ្វីៗសំខាន់ៗ ។

អស់រយៈពេលជាច្រើនឆ្នាំមុនថ្ងៃទី ១៨ មីនា ១៩៧០ ក្រៅពីការងារយោធា លោក លន់ នល់ តែងធ្វើសកម្មភាពជាច្រើនខាងផ្នែកព្រះពុទ្ធសាសនាធ្វើការឧបត្ថម្ភព្រះសង្ឃ និង វត្តអារាមទូទាំងប្រទេសកម្ពុជា ។ ខ្ញុំមិនដឹងថាលោក លន់ នល់ មានការយល់ដឹងផ្នែកព្រះពុទ្ធសាសនា ដល់កំរិតណាទេ គ្រាន់តែនឹកថាគាត់មានជំនឿយ៉ាងមុតមាំលើអច្ឆរិយវត្ថុ អ្នកតា និង ទេវតា ឬ បារមីផ្សេងៗ ។ នៅខែ មករា ១៩៧០ លោក លន់ នល់ បានចាត់ឲ្យនាំនូវម៉ាស៊ីនភ្លើងកំលាំងច្រើនគីឡូវ៉ាត់មួយគ្រឿង ទៅប្រគេនព្រះសង្ឃនៅវត្តកំពង់ទ្រា ក្នុងស្រុកពារាំង ។

លោក លន់ នល់ មានភរិយា ដែលមានគេគោរពរាប់អានច្រើន ឈ្មោះជំទាវ ខេង ។ លោកជំទាវ ខេង បានទទួលមរណភាពនៅឆ្នាំ ១៩៦៩ ។ ក្នុងចំណោមបងប្អូនជាច្រើននាក់ លោក លន់ នល់ ក៏មានប្អូនប្រុសម្នាក់ឈ្មោះ លន់ ណុន ដែលក្រោយមកបានក្លាយជាមនុស្សដៃស្តាំ និង ជាបន្ទុកដ៏ធ្ងន់ផ្នែកនយោបាយរបស់គាត់ផង ។ ខ្ញុំឮគេនិយាយថានៅខែ មីនា ១៩៧០ នោះ លោក លន់ នល់ ហាក់ដូចជាមានការស្ទាក់ស្ទើរក្នុងការធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ។ តាមពាក្យចចាមអារាម លោក លន់ នល់ ស្ថិតនៅក្រោមការបង្ខិតបង្ខំរបស់អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ[41] ដែលនៅក្នុងពេលនោះ កាន់តំណែងជាឧបនាយករដ្ឋមន្ត្រី ហើយជាមិត្តជិតស្និទ្ធរបស់គាត់ ។ ខ្ញុំឮគេថា ដំបូងឡើងគឺ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈទេ ដែលជាអ្នកផ្តួចផ្តើមធ្វើរដ្ឋប្រហារនោះ ។ ខ្ញុំពុំបានដឹងច្បាស់លាស់ដោយលំអិតនៃកិច្ចប្រតិបត្តិការធ្វើរដ្ឋប្រហារនោះទេ ។ ខ្ញុំក៏មិនបានដឹងថាអ្នកអង្គ

[41] អ្នកខ្លះហៅថាព្រះអង្គម្ចាស់ ក៏ប៉ុន្តែតាមការផ្ទៀងផ្ទាត់ ព្រះអង្គមានបិតាជាស្តេចឯមាតាជារាស្ត្រ ដូច្នេះអាចហៅត្រឹមអ្នកអង្គម្ចាស់ សិរិមតៈ ។

ម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ជិតស្និទ្ធជាមួយសម្តេច សីហនុ ដល់កំរិតណា ឬ ទំនាក់ទំនងជាមួយលោក លន់ នល់ បែបណាទេនាសម័យនោះ ។ តាមសៀវភៅប្រវត្តិសាស្ត្រ ខ្ញុំគ្រាន់តែដឹងថាលោក លន់ នល់ និង អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ជាអ្នកបង្កើតគណបក្សនយោបាយមួយក្នុងទសវត្សរ៍ឆ្នាំ ១៩៤០ ឈ្មោះគណបក្សខេមរៈបុណ្យការ ។

## សិរិមតៈ និង ជម្លោះក្នុងរាជវង្ស?

អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ជាសមាជិកមួយអង្គនៃព្រះរាជវង្សានុវង្ស ដែលធ្លាប់បានកាន់តំណែងជាច្រើនលើក ច្រើនគ្រាជារដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការក្នុងរាជរដ្ឋាភិបាលដូចជា នៅក្នុងក្រសួងការពារប្រទេស ក្រសួងអប់រំ ក្រសួងទេសចរណ៍ និង ឃោសនាការជាដើម ។ អ្នកអង្គម្ចាស់ និង សម្តេច សីហនុ ជាបងប្អូនជីទួតមួយ ព្រោះទាំងពីរព្រះអង្គសុទ្ធតែជាចៅទួតរបស់ព្រះករុណាព្រះបាទស៊ីសុវត្ថិ ទាំងអស់ សម្តេច សីហនុ ខាងព្រះមាតា ឯអ្នកអង្គម្ចាស់ សិរិមតៈខាងព្រះបិតា ។ នៅឆ្នាំ ១៩៥២ នៅពេលដែលព្រះករុណាព្រះបាទ នរោត្តម សីហនុ ដឹកនាំព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យនោះ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ[42] កំពុងកាន់តំណែងជារដ្ឋលេខាធិការក្រសួងការពារជាតិ ។

កាលពីសម័យមុន ខ្មែរយើងភាគច្រើនក៏ធ្លាប់បានដឹងថា នៅក្នុងក្រុមរាជ

[42] Ministère de l’Information, Documents, Cabinets Ministériels Khmers, du 18 mars 1945 au 18 mars 1970, op. cit, page 34. ក្នុងគណៈរដ្ឋមន្ត្រីទី១៨ ដឹកនាំដោយព្រះករុណាព្រះបាទ នរោត្តម សីហនុ ពីថ្ងៃទី ២៤ មករា ដល់ ២៨ កក្កដា ១៩៥៣ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ បានឡើងកាន់តំណែងជារដ្ឋមន្ត្រីក្រសួងការពារជាតិ និង ក្រសួងប្រៃសណីយ និង ទូរគមនាគមន៍ តាមឯកសារដដែលទំព័រ ៣៥ ។

វង្សានុវង្សមានការខ្វែងយោបល់គ្នា ឬ មិនចុះសំរុងគ្នាក្នុងការឡើងគ្រងរាជសម្បត្តិ ។ ជាទូទៅគេដឹងថា នៅប្រទេសយើង មានខ្សែរាជវង្សពីរចេញពីព្រះបាទ អង្គឌួង ដែលអាចឡើងសោយរាជ្យបានគឺ ខ្សែព្រះបាទ នរោត្តម មួយ និង មួយទៀត ខ្សែរបស់ព្រះបាទ ស៊ីសុវត្ថិ ។ សម្តេច សីហនុ ទ្រង់ប្រសូតចេញពីខ្សែទាំងពីរគឺ ខ្សែព្រះ នរោត្តម តាមរយៈព្រះបិតា និង ខ្សែព្រះ ស៊ីសុវត្ថិ តាមរយៈព្រះមាតារបស់ព្រះអង្គ ។

ព្រះបាទ អង្គឌួង បានត្រូវទទួលស្គាល់ថា ជាអ្នកគ្រប់គ្រងដែនដីខ្មែរនៅឆ្នាំ ១៨៤៥ ។ ព្រះអង្គបានឡើងគ្រងរាជសម្បត្តិជាផ្លូវការជាព្រះមហាក្សត្រនៅឆ្នាំ ១៨៤៨ បន្ទាប់ពីពេលដែលប្រទេសសៀម និង អាណ្ណាម (ក្រោយមកហៅថា ថៃ និង វៀតណាម) បានបន្ថយការប្រកួតប្រជែងគ្នា ក្នុងការដណ្តើមឥទ្ធិពលលើប្រទេសខ្មែរ ។

ព្រះបាទ អង្គឌួង[43] ជាព្រះមហាក្សត្រទី១ ដែលបានផ្តួចផ្តើមគំនិតចង់ឲ្យបារាំងមកជួយការពារខ្មែរ ចេញពីឥទ្ធិពលរបស់ប្រទេសជិតខាងទាំងពីរ ជាពិសេសពីប្រទេសសៀមនៅសម័យនោះ ។ ទំនាក់ទំនងរបស់ព្រះបាទ អង្គឌួង ដើម្បីបញ្ចប់ឥទ្ធិពលសៀមមកលើកម្ពុជា បានចាប់ផ្តើមនៅឆ្នាំ ១៨៥៣ ដោយការបញ្ជូនមន្ត្រីជាន់ខ្ពស់ខ្មែរពីររូបឈ្មោះ កុយ និង ប៉ែន (ដែលមានខ្សែលោហិតពីជនជាតិព័រទុយហ្គាល់) ទៅកាន់សិង្ហបុរីជាសម្ងាត់ ដើម្បីនាំព្រះរាជសារទៅជូនមន្ត្រីកុងស៊ុលបារាំង ដែលត្រូវបញ្ជូនបន្តទៅថ្វាយព្រះចៅអធិរាជបារាំង ណាប៉ូឡេអុងទី៣ (Napoleon III)[44] ។ បន្ទាប់មក លោក សាល ដឺ ម៉ុងទីញី (Charles de Montigny) អ្នកការទូតបារាំងដែលបានមកដល់កំពង់ផែកំពត នៅថ្ងៃទី ១៨ តុលា

[43] អេង-សុត, ឯកសារមហាបុរសខ្មែរ - ផែនដីព្រះអង្គឌួង - ភ្នំពេញ ១៩៦៩ ទំព័រ១០៧០-១០៩៧ ។

[44] Khin Sok, Le Cambodge entre le Siam et le Vietnam (de 1775 à 1860), Ecole Française d’Extrême-Orient, Paris, 1991, p. 149. ក្នុងសៀវភៅនេះ មិនមាននិយាយពីងារពិតប្រាកដរបស់មន្ត្រីទាំងពីររូបនេះទេ ក៏ប៉ុន្តែជាការជាក់ស្តែង

១៨៥៦ នោះ បានតាក់តែងអត្ថបទអនុសញ្ញាពាណិជ្ជកម្ម និង សាសនា ដើម្បីស្ថាបនាទំនាក់ទំនងជាមួយកម្ពុជា ។ ប៉ុន្តែដោយមានការគាបសង្កត់ពីសៀម ព្រះបាទ អង្គឌួង មិនបានយាងទៅឡាយព្រះហស្តលេខាលើអនុសញ្ញានោះឡើយ ។ នេះជាការប៉ុនប៉ងលើកដំបូងរបស់ព្រះរាជាខ្មែរ ក្នុងការបញ្ចប់ឥទ្ធិពលសៀមមកលើកម្ពុជាប៉ុន្តែមិនបានសម្រេច[45] ។ សន្ធិសញ្ញាអាណាព្យាបាលត្រូវបានចុះហត្ថលេខា នៅថ្ងៃទី ១១ សីហា ១៨៦៣ នៅព្រះរាជវាំងឧដុង្គ រវាងព្រះបាទ នរោត្តម និង លោកឧត្តមនាវី ដឺឡាក្រង់ឌីយ៉ែ (De la Grandière) ដែលជាទេសាភិបាលបារាំងនៅកូសាំងស៊ីន (Gouverneur de la Cochinchine) ។

ព្រះបាទ អង្គឌួង មានព្រះរាជបុត្របីព្រះអង្គ ដែលប្រសូតចេញពីព្រះមហេសីផ្សេងៗគ្នាគឺ ព្រះបាទ នរោត្តម ព្រះបាទ ស៊ីសុវត្ថិ និង ព្រះអង្គម្ចាស់ ស៊ីវត្ថា ។ ក៏ប៉ុន្តែ មានតែព្រះរាជវង្សរបស់ព្រះបាទ នរោត្តម និង ព្រះបាទ ស៊ីសុវត្ថិទេ ដែលអាចឡើងគ្រងរាជសម្បត្តិបាន ដោយហេតុថា ព្រះអង្គម្ចាស់ ស៊ីវត្ថា ធ្លាប់បានធ្វើការបះបោរប្រឆាំងព្រះបាទ នរោត្តម ។ តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានតែព្រះរាជវង្សានុវង្ស ដែលចេញមកពីខ្សែព្រះរាជបុត្រច្បងទាំងពីរព្រះអង្គនៃព្រះបាទ អង្គឌួង នោះទេ ដែលអាចឡើងគ្រងរាជសម្បត្តិបាន ។ ក្រោយមករដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ក៏បានចែងដូចរដ្ឋធម្មនុញ្ញមុននេះដែរ ក្នុងការឡើងគ្រងរាជសម្បត្តិ ។

តាមប្រពន្ធ័រាជានិយមនៃប្រទេសកម្ពុជាយើង គេពុំបានកំណត់ឲ្យមានរាជឱរសស្នងរាជ្យ(Prince héritier) ដែលអាចឡើងគ្រងរាជសម្បត្តិដោយស្វ័យប្រវត្ត

---

មន្ត្រីជាន់ខ្ពស់ថ្នាក់នេះសុទ្ធតែមានងារ យ៉ាងហោចណាស់ក៏ថ្នាក់ស្មើឧកញ៉ាដែរ ។ នៅក្នុងឯកសារមហាបុរស គេអាចឃើញមានឧកញ៉ាពិភក្តិមន្ត្រី កុយ មួយរូបដែរ ក្នុងរជ្ជកាលព្រះបាទ អង្គឌួង ។

[45] ស៊ន សំណាង, អនុសញ្ញាពាណិជ្ជកម្ម និង សាសនា ថ្ងៃទី ១៨ តុលា ១៨៥៦ នៅក្នុងទស្សនាវដ្តីរាជបណ្ឌិតសភាកម្ពុជា លេខ ១ ឆ្នាំ ២០០២ ទំព័រ ៨៤-៩៣ ។

ជាព្រះមហាក្សត្រថ្មី នៅពេលដែលព្រះមហាក្សត្រគ្រងរាជ្យទ្រង់ចូលទីវង្គតនោះឡើយ ។ តាមប្រព័ន្ធបែបនេះ នៅពេលដែលព្រះមហាក្សត្រគ្រងរាជ្យសុគត ក្រុមប្រឹក្សារាជសម្បត្តិជាអ្នកជ្រើសរើសព្រះមហាក្សត្រថ្មី ក្នុងចំណោមព្រះអង្គម្ចាស់ទាំងឡាយ ដែលចេញមកពីខ្សែទាំងពីរនៃព្រះរាជវង្សានុវង្សនេះ ។ នេះជាប្រព័ន្ធរាជាធិបតេយ្យជ្រើសតាំង (Monarchie élective) ។ មានតែព្រះអង្គម្ចាស់ទេដែលមានសិទ្ធិជាបេក្ខជនក្នុងតំណែងព្រះមហាក្សត្រ ចំណែកឯព្រះអង្គម្ចាស់ក្សត្រីពុំមានសិទ្ធិឡើងគ្រងរាជសម្បត្តិឡើយ ។

គួររំលឹកថា ក្រៅពីព្រះនាង លីវ យី ឬ ព្រះនាង សោមា ដែលជាព្រះមហាក្សត្រីយានីដំបូងនៃសម័យនគរភ្នំ (សតវត្សទី១ ដល់គ.ស. ៥៥០) ក៏មានព្រះមហាក្សត្រីយានីពីរអង្គទៀតគឺព្រះនាង ជ័យទេវី នៅចុងសម័យចេនឡា (គ.ស. ៥៥០-៨០២) និង ព្រះអង្គម្ចាស់ក្សត្រីព្រះនាម អង្គម៉ី បានឡើងសោយរាជ្យមួយរយៈដែរ នៅចុងសម័យឧដុង្គ ។ ប្រហែលដោយសារមានបទពិសោធន៍ដ៏ជូរចត់តាំងពីពេលនោះមក ទើបព្រះអង្គម្ចាស់ក្សត្រីលែងមានសិទ្ធិឡើងគ្រងរាជ្យជារៀងរហូត ។ តាមប្រព័ន្ធ ដែលគ្មានការចាត់តាំងរាជឱរសស្នងរាជ្យឲ្យឡើងគ្រងរាជ្យដោយស្វ័យប្រវត្តនេះ បានធ្វើឲ្យព្រះអង្គម្ចាស់ទាំងឡាយ អាចក្លាយជាបេក្ខជនព្រះមហាក្សត្របាន ។ ព្រះបុត្រាមួយអង្គៗអាចមានសិទ្ធិឡើងគ្រងរាជ្យ មានសិទ្ធិអំណាចប្រហាក់ប្រហែលគ្នាគឺ គ្មានអង្គណាធំជាងអង្គណាពេកទេ ។ ម្យ៉ាងទៀតព្រះក្សត្រាទាំងនោះ ក៏តែងមានមន្ត្រីធំ មេទ័ព ឬ អ្នកមានឥទ្ធិពលជាមនុស្សជំនិតរៀងៗខ្លួន ។ មនុស្សជំនិត ទាំងនោះ ក៏តែងខឹតខំប្រណាំងប្រជែងគ្នាជំរុញបេក្ខជនដែលគេគាំទ្ររៀងៗខ្លួនឲ្យបានឡើងសោយរាជ្យ ។ ទាំងនេះក៏អាចនាំឲ្យមានជម្លោះរាជបល្ល័ង្កជាញឹកញាប់ដែរ ។ ប៉ុន្តែប្រព័ន្ធនេះ ក៏មានចំណុចវិជ្ជមានដែរ ប្រសិនបើការជ្រើសរើសនោះ ប្រព្រឹត្តទៅដោយយុត្តិធម៌ ព្រោះការជ្រើសរើសដោយការស្រុះ

ស្រួលមូលមតិគ្នា នៅក្នុងក្រុមប្រឹក្សារាជសម្បត្តិជាសមូហភាពទៅលើបេក្ខភាពដែលមានគុណសម្បត្តិខ្ពស់ជាងគេ ក៏ជាការចាប់បង្ខំឲ្យភាគីពាក់ព័ន្ធក្នុងការជ្រើសរើសនោះ ដែលភាគច្រើនសុទ្ធតែជាអ្នកមានឥទ្ធិពលនៅក្នុងព្រះរាជាណាចក្រ គ្មានលេស ឬ ហេតុផលអ្វីក្រៅពីទទួលយកសេចក្តីសម្រេចទាំងអស់គ្នាតែប៉ុណ្ណោះ ។

ដូច្នេះដោយយោងលើចំណុចវិជ្ជមាននេះ ទើបការស្នងរាជសម្បត្តិនៅប្រទេសកម្ពុជាយើង បានស្ថិតនៅក្នុងប្រព័ន្ធជ្រើសតាំង ដែលអាចហៅថាតាមបែបប្រជាធិបតេយ្យក៏បាន ។ ក៏ប៉ុន្តែជួនកាលក៏មានករណីពិសេស ដែលព្រះមហាក្សត្រគ្រងរាជ្យ នៅពេលហៀបនឹងសុគត ផ្តាំផ្ញើឲ្យព្រះរាជបុត្រអង្គណាមួយឡើងសោយរាជ្យតពីព្រះអង្គទៅ ។ ក្នុងករណីនេះ ព្រះក្សត្រាអង្គនោះនឹងអាចក្លាយជាអ្នកស្នងរាជសម្បត្តិបាន ។ ជាទម្លាប់ព្រះមហាក្សត្រគ្រងរាជ្យនោះ តែងជ្រើសរើសព្រះរាជបុត្រច្បង ក្នុងចំណោមព្រះរាជបុត្រច្រើនអង្គ ។ គួរកត់សំគាល់ថាព្រះមហាក្សត្រមួយអង្គៗតែងមានព្រះមហេសីច្រើនអង្គ ដូច្នេះទើបព្រះអង្គតែងតាំងព្រះមហេសីមួយអង្គឲ្យធ្វើធំជាងគេ លើព្រះមហេសីឯទៀត ជាព្រះរាជអគ្គមហេសី ។ ដោយសារព្រះមហាក្សត្រមានព្រះមហេសីច្រើនព្រះអង្គ ព្រះអង្គក៏មានព្រះរាជបុត្រា និងបុត្រីច្រើនអង្គដែរ ។

នៅពេលព្រះបាទ នរោត្តម សុគតនៅឆ្នាំ ១៩០៤ ការប្រជុំក្រុមប្រឹក្សារាជសម្បត្តិ ដែលនៅក្រោមអធិបតីភាពរបស់លោករេស៊ីដង់ជាន់ខ្ពស់ (Résident supérieur) បារាំង បានជ្រើសរើសសម្តេចព្រះ ស៊ីសុវត្ថិ ជាព្រះអនុជ ឬ ប្អូនឲ្យឡើងសោយរាជ្យជាបន្ត ។ ក្រោយមកទៀត មុននឹងព្រះអង្គចូលទីវង្គត ព្រះករុណាព្រះបាទ ស៊ីសុវត្ថិ បានបន្សល់ទុកនូវមតកសាសន៍ (Testament)[46] ឬ បណ្តាំ

[46] Sorn Samnang, L’évolution de la société cambodgienne entre les deux guerres mondiales (1919-1939), op.cit, pp. 93-95.

ជាលាយលក្ខណ៍អក្សរ សម្រាប់ឲ្យក្រុមប្រឹក្សារាជសម្បត្តិជ្រើសតាំងព្រះរាជបុត្ររបស់ព្រះអង្គគឺ សម្តេចព្រះ មុនីវង្ស ឲ្យគ្រងរាជ្យជាព្រះមហាក្សត្រជំនួសតទៅទៀត ។ នៅមុនពេលដែលព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស សុគត ទ្រង់ផ្តាំផ្ញើឲ្យរាជបុត្រព្រះអង្គព្រះនាមព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត ឡើងគ្រងរាជ្យជំនួសតទៅទៀតគឺបំភ្លេចខ្សែព្រះ នរោត្តម ចោលទាំងស្រុងតែម្តង ។ ក៏ប៉ុន្តែ អាជ្ញាធរបារាំងប្រឆាំងនឹងការផ្ទេររាជសម្បត្តិនេះ ។ ប្រសិនបើគ្មានការប្រឆាំង ពីអាជ្ញាធរបារាំងទេនោះ ប្រហែលជាព្រះរាជវង្សខ្សែព្រះ ស៊ីសុវត្ថិ នឹងត្រូវបន្តសោយរាជ្យតទៅទៀត ។ សម្តេច សីហនុ បានទទួលស្គាល់អំពីទំនាស់រាជវង្សនេះ ។ នៅក្នុងសៀវភៅ ដែលព្រះអង្គទ្រង់និពន្ធក្នុងឆ្នាំ ១៩៧២ ក្រោមចំណងជើងថា "សេ អ៊ី អា ប្រឆាំងប្រទេសកម្ពុជា" សម្តេច សីហនុ បានទំលាក់កំហុសទៅលើរដ្ឋាភិបាលអាណាព្យាបាលបារាំង ពាក់ព័ន្ធទៅនឹងការឡើងសោយរាជ្យរបស់ព្រះអង្គ ដោយលើកឡើងថាបារាំងជាអ្នកបង្កឲ្យមានការបែកបាក់ក្នុងព្រះរាជវង្ស ។ តាមពិត ពួកបារាំងយល់ថាត្រូវបង្វែររាជបល្ល័ង្កនេះទៅខ្សែព្រះ នរោត្តម ម្តងវិញ ។ បារាំងបានជ្រើសរើសផ្លូវកណ្តាល ដើម្បីជៀសវាងកុំឲ្យមានការផ្ទន់ស្រាលទៅខ្សែព្រះរាជវង្សណាមួយ ។ ដូច្នេះហើយបានជានៅឆ្នាំ ១៩៤១ នៅពេលដែលព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ទ្រង់ចូលទីវង្គតនោះ បារាំងបានសម្លឹងឃើញបេក្ខភាពរបស់ព្រះអង្គម្ចាស់ សីហនុ ក្នុងការឡើងគ្រងរាជសម្បត្តិជាបន្ត ។

ព្រះអង្គម្ចាស់ សីហនុ មានព្រះជន្ម ១៩ ព្រះវស្សាតែប៉ុណ្ណោះ គ្មានបទពិសោធន៍ក្នុងឆាកនយោបាយនៅឡើយទេ ដែលបារាំងជឿថាពួកគេអាចមានឥទ្ធិពលលើព្រះអង្គ ឬ អាចញាក់ខ្សែឲ្យព្រះអង្គធ្វើតាមបំណងបាន ។ ព្រះអង្គម្ចាស់ សីហនុ មានបិតាជាខ្សែព្រះ នរោត្តម និង ព្រះមាតាជាខ្សែព្រះ ស៊ីសុវត្ថិ ។ សម្តេច សីហនុ ជាព្រះរាជបុត្ររបស់ព្រះបាទ នរោត្តម សុរាម្រឹត ដែលមានព្រះបាទ

នរោត្តម ជាព្រះឯឃ្យកោ ឬ ជីតា ។ សម្តេច សីហនុ ក៏ជាព្រះរាជបុត្ររបស់សម្តេចព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ កុសុមៈ ដែលជាព្រះរាជបុត្រីរបស់ព្រះករុណាព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ឬ ដែលមានព្រះបាទ ស៊ីសុវត្ថិ ជាព្រះឯឃ្យកោផងដែរ ។ ការជ្រើសរើសយកព្រះអង្គម្ចាស់ នរោត្តម សីហនុ ជាព្រះមហាក្សត្រ និង ការជំរុះបេក្ខភាពរបស់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត នោះបានធ្វើឲ្យព្រះរាជវង្សានុវង្សខ្សែខាងព្រះ ស៊ីសុវត្ថិ មានការមិនពេញចិត្ត ។ គួរបញ្ជាក់ថាព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត ជាព្រះអនុជបង្កើត ឬ ប្អូនបង្កើតរបស់ព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ កុសុមៈ ព្រះមាតារបស់សម្តេច សីហនុ ដូច្នេះ ព្រះអង្គជាព្រះមាតុលា ឬ ឪពុកមាខាងម្តាយរបស់សម្តេច សីហនុ ។ ព្រះអងម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត មានព្រះឋានៈជាសម្តេចក្រុមព្រះ រហូតដល់ព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ ។

បើតាមសម្តេច សីហនុ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ដែលជាខ្សែព្រះស៊ីសុវត្ថិ គាំទ្របេក្ខភាពព្រះ ស៊ីសុវត្ថិ មុនីរ៉េត ក្នុងតំណែងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ ការឡើងសោយរាជ្យរបស់ព្រះករុណា នរោត្តម សីហនុ បានធ្វើឲ្យអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ កើតក្តីទោមនស្ស ។ ព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ អាចបកស្រាយថាជាការសងសឹកនៃខ្សែព្រះ ស៊ីសុវត្ថិ ប្រឆាំងនឹងខ្សែព្រះនរោត្តម គឺ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ប្រឆាំងនឹងសម្តេចព្រះ នរោត្តម សីហនុ ។

នៅក្នុងសៀវភៅដដែលនោះ សម្តេច សីហនុ ទ្រង់បានបញ្ចេញនូវប្រតិកម្មទីមួយចំពោះរដ្ឋប្រហារ ១៨ មីនា ១៩៧០ ដូចតទៅនេះ៖ "គ្មានអ្វីឆ្ងល់ចំពោះខ្ញុំទេ ដែលថាអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ជាអ្នកធ្វើរដ្ឋប្រហារនោះ[47] ។ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ មានការស្អប់ខ្ពើមខ្ញុំតាំងពីតូចមកម្ល៉េះ ព្រោះគេជឿថាខ្ញុំមិនត្រូវ

[47] Norodom Sihanouk, La C.I.A. contre le Cambodge, op.cit, p. 19.

ឡើងសោយរាជ្យទេ ព្រោះរាជសម្បត្តិត្រូវធ្លាក់ទៅសម្តេច ស៊ីសុវត្ថិ មុនីវ៉េត ដែលត្រូវជាឪពុកមារបស់គេ” ។ ជាច្រើនឆ្នាំក្រោយមកក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ នៅភាពជាជនភៀសខ្លួន ខ្ញុំបានស្គាល់គូស្វាមីភរិយាមួយគូ ដែលព្រះស្វាមីជាព្រះបុត្រានៃអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ និង ព្រះមហេសីជាបុត្រីនៃសម្តេច នរោត្តម សីហនុ ។ ខ្ញុំនឹកក្នុងចិត្តថាខ្សែនៃព្រះរាជវង្សានុវង្សទាំងពីរ បានស្រុះស្រួលជានានឹងគ្នាវិញហើយ ។

# សម្តេច សីហនុ លែងទុកចិត្តអាមេរិក

គួររំលឹកថា នៅមុនរដ្ឋប្រហារថ្ងៃ ១៨ មីនា នោះ មានក្រុមអ្នកនយោបាយមួយចំនួនដែលមិនពេញចិត្តចំពោះនយោបាយដឹកនាំរបស់សម្តេច សីហនុ ក្នុងរយៈពេលកន្លងមក ។ នៅឆ្នាំ ១៩៥៥ បន្ទាប់ពីព្រះអង្គបានបង្កើតចលនានយោបាយរបស់ព្រះអង្គដែលមានឈ្មោះថា“សង្គមរាស្ត្រនិយម” និង បន្ទាប់ពីបានជម្រុះចោលនូវគណបក្សនយោបាយមួយចំនួននោះមក តាមរយៈការបោះឆ្នោតប្រជាមតិ ឬបាតុកម្មនានានោះ សម្តេច សីហនុ បានធ្វើការដឹកនាំប្រទេសតាមរបៀបមួយបែបផ្ទាល់របស់ព្រះអង្គ ។

នៅឆ្នាំ ១៩៦៣ សម្តេចធ្វើជាតូបនីយកម្មវិស័យធនាគារ ធានារ៉ាប់រង ការនាំចេញនាំចូល និង ផ្នែកឧស្សាហកម្មមួយចំនួនទៀត ។ សម្តេចបានបង្កើតក្រុមហ៊ុនរដ្ឋជាច្រើន ក្នុងនោះមានក្រុមហ៊ុនសុរាគារខ្មែរ និង រោងចក្រធ្វើកែវ ដែលខ្ញុំបានចូលធ្វើការដំបូងនាចុងឆ្នាំ ១៩៦៨ ។ សម្តេច សីហនុ បានកាត់ទំនាក់ទំនងជាមួយសហរដ្ឋអាមេរិក ដែលធ្វើឲ្យប្រទេសយើងបាត់បង់នូវជំនួយយោធា និងសេដ្ឋកិច្ចរបស់ប្រទេសមហាអំណាចនោះ ។ សម្តេចបានរឹតចំណងមេត្រីភាពជាមួយប្រទេសកុម្មុយនីស្តដូចជា ប្រទេសចិន សហភាពសូវៀត ប្រទេសអឺរ៉ុបខាង

កើត ប្រទេសគុយបា កូរ៉េខាងជើង វៀតណាមខាងជើង និង វៀតកុង ។ ក្នុងផ្នែកលោកខាងលិច សម្តេចបានធ្វើការពង្រឹងចំណងមេត្រីភាពជាមួយបារាំង ដែលទ្រង់យកមកជំនួសសហរដ្ឋអាមេរិក ។ ព្រះអង្គមានការគោរពយ៉ាងខ្លាំងចំពោះលោកឧត្តមសេនីយ ដឺហ្គោល[48] ។

សម្តេច សីហនុ មានហេតុផលក្នុងការប្រឆាំងនឹងសហរដ្ឋអាមេរិក និងសម្ពន្ធមិត្តរបស់គេគឺ ប្រទេសវៀតណាមខាងត្បូង និង ប្រទេសថៃ ដែលបានគាំទ្រក្រុមបះបោរប្រឆាំងព្រះអង្គមួយក្រុមមានឈ្មោះថាក្រុមខ្មែរសេរី ។ ក្រុមខ្មែរសេរី ធ្វើវិទ្ធង្សនាប្រឆាំងព្រះអង្គនៅតាមទល់ដែនខ្មែរ-ថៃ និង ខ្មែរ-វៀតណាមខាងត្បូង ។ ចលនាខ្មែរសេរីនេះ ដឹកនាំដោយលោក សឺង ង៉ុកថាញ់ ដែលត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីនៅឆ្នាំ ១៩៤៥ ដោយសារកងទ័ពជប៉ុន ដែលចូលមកដណ្តើមបានអំណាចមួយរយៈពេលយ៉ាងខ្លីពីបារាំង នៅក្នុងប្រទេសកម្ពុជា ។ បន្ទាប់មកលោក សឺង ង៉ុកថាញ់ ត្រូវបានបារាំងចាប់ដាក់គុក ។ ក្រោយមកគាត់បានភៀសខ្លួនទៅប្រទេសវៀតណាម ។ នៅទសវត្សរ៍ឆ្នាំ ១៩៥០ លោក សម សារី ដែលធ្លាប់ជាជំនួយការដ៏ជិតស្និទ្ធម្នាក់របស់សម្តេច សីហនុ នៅពេលបង្កើតចលនាសង្គមរាស្ត្រនិយមនោះ ក៏បានរត់ទៅចូលរួមជាមួយនឹងលោក សឺង ង៉ុកថាញ់ ។ សូមរំលឹកថាលោក សម សារី ជាឪពុករបស់លោក សម រង្ស៊ី ដែលជាមេគណបក្សប្រឆាំងមួយនៅក្នុងប្រទេសកម្ពុជា ។

កាលសម័យនោះ ក៏មានគំរោងការបះបោររបស់លោក ដាប ឈួន ឈ្មោះផ្លូវការ ឈួន ម្ចុលពេជ្រ ស្តេចត្រាញ់មួយរូប នៅខេត្តសៀមរាប ដោយមានការពាក់

---

[48] Charles de Gaulle (22 November 1890 – 9 November 1970) founded the French Fifth Republic in 1958 and served as its first President from 1959 to 1969. លោក ដឺហ្គោល ជាឧត្តមសេនីយ និង រដ្ឋបុរសបារាំង ដែលបានដឹកនាំកងកម្លាំងបារាំងសេរី ប្រឆាំងកងទ័ពអាឡឺម៉ង់នៅសង្គ្រាមលោកលើកទី២ ។ លោកជាស្ថាបនិកនៃសាធារណរដ្ឋបារាំងទី៥ និង ជាប្រធានាធិបតីទី១នៃសាធារណរដ្ឋនេះ ពីឆ្នាំ ១៩៥៩ ដល់ ១៩៦៩ ។

ព័ន្ធជាមួយសហរដ្ឋអាមេរិក ប្រទេសវៀតណាមខាងត្បូង និង ប្រទេសថៃ ។ គំរោងក្បត់របស់លោក ដាប ឈួន បានត្រូវវែកមុខ ហើយលោក ដាប ឈួន ក៏ត្រូវបានសំលាប់ក្នុងកិច្ចប្រតិបត្តិយោធាមួយដែលដឹកនាំឡើងដោយលោក លន់ នល់ ។ នៅសម័យនោះ លោក លន់ នល់ ជាមនុស្សម្នាក់ដែលបានទទួលការទុកចិត្តយ៉ាងខ្លាំងពីសម្តេច នរោត្តម សីហនុ ។

មានគំរោងការមួយទៀតក្នុងការធ្វើឃាតសម្តេចព្រះ នរោត្តម សីហនុ និង ព្រះវរបិតា ព្រមទាំងព្រះវរមាតារបស់ព្រះអង្គ ដោយក្រុមសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិក ។ គំរោងប៉ុនប៉ងធ្វើឃាតនោះ បានកើតឡើងនៅថ្ងៃទី ៣១ សីហា ១៩៥៩ ។ នៅពេលនោះ មានការនាំយកមកថ្វាយព្រះករុណាព្រះបាទ សុរាម្រឹត និង សម្តេចព្រះមហាក្សត្រយានី កុសុមៈ នូវជង្វាយដែលគេដាក់ក្នុងប្រអប់លាបម្រ័ក្សណ៍ខ្មុកពីរយ៉ាងខ្មៅរលោង ។ ព្រះអង្គម្ចាស់ វក្កតិវិវណ្ណ ប្រធានព្រះរាជពិធីការបានបើកប្រអប់ទីមួយ រំពេចនោះប្រអប់ម្រ័ក្សណ៍ខ្មុកក៏ផ្ទុះឡើងភ្លាម ធ្វើឲ្យព្រះអង្គម្ចាស់សុគត ព្រមគ្នាជាមួយមន្ត្រីព្រះបរមរាជវាំងម្នាក់ទៀតនៅនឹងកន្លែង ។ ជាសំណាងល្អ ព្រះករុណាព្រះបាទ សុរាម្រឹត និង សម្តេចព្រះមហាក្សត្រយានី បានរួចព្រះជន្មផុតពីការប៉ុនប៉ងធ្វើគត់នេះ ដោយសារតែព្រះអង្គទាំងពីរ ទ្រង់ជាប់រវល់នៅក្នុងបន្ទប់ផ្សេងទៀតនៃព្រះរាជដំណាក់នៅក្បែរទីកើតហេតុនោះ ។ កាលនោះ ព្រះមហាក្សត្រ និង ព្រះមហាក្សត្រយានីទ្រង់កំពុងប្រទានព្រះរាជសវនាការចំពោះលោក សឺន សាន អគ្គទេសាភិបាលនៃធនាគារជាតិកម្ពុជា និង ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសដែលបានចូលមកក្រាបថ្វាយបង្គំលា មុននឹងចេញដំណើរទៅបំពេញបេសកម្មនៅក្រៅប្រទេស ។ ម្ភៃឆ្នាំក្រោយមក លោក សឺន សាន បានក្លាយជាប្រធានចលនាតស៊ូប្រឆាំងវៀតណាម និង ជាប្រធានចលនាតស៊ូរបស់ខ្ញុំ ហើយបានរៀបរាប់ពីព្រឹត្តិការណ៍នេះប្រាប់ពួកយើង ។

ការកើតឡើងជាញឹកញាប់នូវផែនការក្បត់ ឬ ផែនការធ្វើឃាតព្រះអង្គ ដោយពួកខ្មែរសេរី ដោយមានភស្តុតាងជាប់ពាក់ព័ន្ធជាមួយសហរដ្ឋអាមេរិក និង ប្រទេសលោកខាងលិចខ្លះ ជាហេតុផលនាំឲ្យព្រះអង្គលែងទុកចិត្តអាមេរិក ។ ចំណែកសហរដ្ឋអាមេរិក នៅសម័យនោះ ត្រូវការស្វែងរកនូវសម្ព័ន្ធភាពរឹងមាំរបស់ខ្លួននៅកម្ពុជា ដែលមាននិន្នាការស្រឡាញ់លោកសេរី ប្រឆាំងកុម្មុយនីស្ត និង ដែលសុខចិត្តដាក់ខ្លួនជារណបអាមេរិក ។ ក្រុមអ្នកនយោបាយខ្មែរដែលមាននិន្នាការទៅរកសហរដ្ឋអាមេរិកនេះ ត្រូវសម្តេច សីហនុ ឲ្យឈ្មោះថាពួកខ្មែរខៀវ ។ ពួកខ្មែរខៀវនោះ ក៏ត្រូវចោទប្រកាន់ថាជាពួកសាធារណរដ្ឋ ជាអ្នកផ្តួលរំលំរបបរាជានិយម ឬ ព្រះរាជបល្ល័ង្គ ដែលជាអំពើក្បត់ជាតិ ។ ខ្មែរខៀវណា ឬ អ្នកសាធារណរដ្ឋនិយមណា ដែលរកឃើញថាមានទំនាក់ទំនងជាមួយខ្មែរសេរីរបស់លោក សឺង ង៉ុកថាញ់ ត្រូវបានចាប់ដាក់គុក ឬ ត្រូវសម្លាប់ចោល ។

នៅសម័យនោះ សម្តេច សីហនុ បានលើកទឹកចិត្តឲ្យប្រជារាស្ត្រ ធ្វើការប្រឆាំងនឹងពួកខ្មែរសេរីយ៉ាងខ្លាំងក្លាបំផុត ។ នៅក្នុងការផ្សាយនៃវិទ្យុជាតិមានកម្មវិធីបើកឲ្យប្រជាពលរដ្ឋ មកស្រែកជេរប្រឆាំងនឹងពួកខ្មែរសេរីជារៀងរាល់ថ្ងៃ ។ ការស្រែកជេរតាមវិទ្យុជាតិនេះ ជាការប្រឆាំងតទល់នឹងការឃោសនារបស់វិទ្យុខ្មែរសេរី ដែលវាយប្រហារសម្តេច សីហនុ ពីតំបន់ភ្នំដងរែក នៅតាមទល់ដែនខ្មែរ-ថៃ ។ បន្ទាប់ពីរដ្ឋប្រហារ ខែ មីនា ១៩៧០ លោក សឺង ង៉ុកថាញ់ បានត្រឡប់មកប្រទេសកម្ពុជាវិញ ហើយបានទទួលតំណែងជានាយករដ្ឋមន្ត្រីរបស់លោក លន់ នល់ នៅឆ្នាំ ១៩៧២ ។

# ខ្មែរក្រហម និង ពួកបញ្ញវន្ត

ក្រៅពីពួកខ្មែរខៀវ សម្តេច សីហនុ ក៏បានលាបពណ៌ឲ្យអ្នកនយោបាយខ្មែរមួយក្រុមទៀត ដែលមានមនោគមវិជ្ជាគាំទ្រពួកកុម្មុយនីស្ត ឬ សង្គមនិយមជាពួកខ្មែរក្រហម ″Khmer Rouge″ ។ ក្នុងមជ្ឈដ្ឋានអន្តរជាតិ គេស្គាល់ពួកខ្មែរក្រហមនេះថាជា ″Khmer Rouge″ ព្រោះសម្តេចសីហនុ ធ្លាប់ប្រើឈ្មោះជាភាសាបារាំងនេះជារៀងរហូតមក ។ កាលក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ នោះ មានមនុស្សម្នាក់ដែលមានការចេះដឹងដ៏ល្អបង្គួរដែរ ហើយដែលមានស្រុកកំណើតនៅជាមួយខ្ញុំ និង មានអាយុច្រើនជាងខ្ញុំ បានសួរខ្ញុំថា អ្វីដែលហៅថាខ្មែរក្រហមនោះ ព្រោះតែគេមានមុខពណ៌ក្រហម ឬ ស្បែកពណ៌ក្រហម ឬ យ៉ាងណា? ខ្ញុំនឹកក្នុងចិត្តថា មនុស្សដែលមានការចេះដឹងប៉ុណ្ណឹងដែរ មិនគួរលើកយកសំណួរបែបនេះមកសួរខ្ញុំសោះ ព្រោះសំណួរនេះសំរាប់តែក្មេងមិនចេះដឹង ឬ អ្នកមិនចេះអក្សរទេ ។

នៅពេលដែលសម្តេច សីហនុ ខិតចូលជិតពួកប្រទេសកុម្មុយនីស្ត និង ដកព្រះអង្គឆ្ងាយចេញពីពួកលោកខាងលិច សម្តេចក៏ចាត់ឲ្យមានការចាប់ខ្មែរក្រហមដាក់គុកដែរ ។ បញ្ញវន្ត មានគ្រូបង្រៀន ឬ សាស្ត្រាចារ្យមួយចំនួនធំ បានត្រូវចាប់ខ្លួន និង ជាប់ឃុំឃាំងក្នុងពន្ធនាគារ ។ ក្នុងចំណោមនោះ ក៏មានឪពុកមាខ្ញុំម្នាក់ដែរដូចខ្ញុំបានរៀបរាប់នៅវគ្គមុនរួចហើយ ។ គាត់ត្រូវចាប់ខ្លួន និង ជាប់ឃុំឃាំងក្នុងពន្ធនាគារ ដោយសារតែគាត់បានទៅធ្វើការសិក្សាផ្នែកបច្ចេកទេសនៅប្រទេសចិនតែប៉ុណ្ណោះ ។ បញ្ញវន្តមួយចំនួនទៀតរត់គេចខ្លួនពីការចាប់ខ្លួន និង ចេញទៅរួមដៃគ្នាជាមួយពួកខ្មែរក្រហមនៅតាមមូលដ្ឋានសម្ងាត់របស់ពួកគេ ។ ពួកទាំងនោះ រាប់ទាំងមេខ្មែរក្រហមធំៗដូចជា ប៉ុល ពត ឬ សាឡុត ស ខៀវ សំផន សុន សេន អៀង សារី ហ៊ូ នឹម ហ៊ូ យន់ ជាដើម ។ លោក ខៀវ សំផន និង ដៃគូរបស់គាត់ពីរ

នាក់ទៀត បានបាត់ខ្លួនពីក្រុងភ្នំពេញនៅឆ្នាំ ១៩៦៧ ដែលនៅពេលនោះ មជ្ឈដ្ឋានទូទៅមានជំនឿថាអ្នកទាំងបីនាក់នោះ ត្រូវបានប៉ូលីសរបស់សម្តេច សីហនុ សម្លាប់ស្លាប់បាត់ទៅហើយ ។ បញ្ញវន្តដែលមាននិន្នាការសង្គមនិយម ដែលបានទៅសិក្សានៅប្រទេសបារាំងមួយចំនួនត្រូវបានពួកនិស្សិត ឬ សិស្សានុសិស្សមួយចំនួនធំទទួលស្គាល់ថាជាបញ្ញវន្តស្អាតស្អំ មានចិត្តស្រឡាញ់ជាតិ មានចិត្តគំនិតស្រឡាញ់បដិវត្តន៍ប្រឆាំងនឹងមនោគមវិជ្ជារបស់លោកខាងលិច ។ បញ្ញវន្តទាំងនោះ ខ្លះជាសាស្ត្រចារ្យ បានធ្វើការអប់រំណែនាំយើងក្មេងៗឲ្យស្អប់អារ្យធម៌លោកសេរី ឬលោកខាងលិច ដែលគេចាត់ទុកជាពួកអាណានិគមនិយម និង ចក្រព័ត្រនិយមថ្មី ។ លោកគ្រូសាស្ត្រាចារ្យខ្លះអប់រំឲ្យយើងបោះបង់ចោលនូវអ្វីៗមកពីលោកខាងលិច ដូចជាប្រៀបធៀបថាប៊ិកគួករបស់យើង មានរសជាតិឆ្ងាញ់ជាងផ្លែប៉ោម ដែលមកពីប្រទេសលោកខាងលិចទៅទៀតគឺ ពួកគាត់ចង់អប់រំឲ្យយើងបោះបង់ ឬ កុំប្រើប្រាស់ផលិតផលប្រណិតដែលត្រូវនាំចូលពីបរទេស ។

នៅប្រទេសកម្ពុជាយើង នាសម័យនោះ ពិភពអ្នកនយោបាយមានចំនួនតិចតួចនៅឡើយ ក៏ប៉ុន្តែពួកគេឋិតនៅក្នុងវណ្ណៈខ្ពស់ ដែលភាគច្រើននៅដាច់ពីប្រជាជន ។ ប្រជាពលរដ្ឋយើងដែលជាអ្នកស្រុកធម្មតា តែងតែគោរពអ្នកធំដែលគេជឿថាសុទ្ធតែបានសាងបុណ្យបារមីពីជាតិមុន ទើបបានជាមានភព្វសំណាងមកកើតជាអ្នកធំក្នុងជាតិនេះ ។ នៅសម័យនោះ គេសង្កេតឃើញបញ្ញវន្តយើងមានពីរប្រភេទគឺ បញ្ញវន្តមួយផ្នែក ដែលទទួលការសិក្សាក្នុងស្រុកខ្មែរតាមបែបព្រះពុទ្ធសាសនា និង បញ្ញវន្តមួយផ្នែកទៀត ដែលបានទទួលការសិក្សានៅបស្ចឹមប្រទេស ។

បញ្ញវន្តប្រភេទទីមួយ ឋិតនៅក្នុងចំណោមព្រះសង្ឃ ដែលបានសិក្សាធម៌វិន័យ ដែលគេអាចហៅថា "ធម៌ថ្មី"គឺជាអ្នករៀនសូត្រចេះចាំច្បាស់លាស់នូវព្រះត្រៃបិដក ហើយដែលអាចបកប្រែនូវធម៌របស់ព្រះសាម្មាសម្ពុទ្ធជាភាសាខ្មែរបានយ៉ាង

ច្បាស់លាស់ ។ បញ្ញវន្តទាំងនោះ មានជំនឿថាព្រះពុទ្ធ ព្រះអង្គមិនបានហាមប្រាម មិនឲ្យព្រះសង្ឃ ឬ ពុទ្ធបរិស័ទពាក់ពន្ធ័នឹងសកម្មភាពនយោបាយនោះទេ ។ ផ្ទុយទៅវិញ ពួកបញ្ញវន្តទាំងនោះជឿថា ការចូលរួមក្នុងសកម្មភាពនយោបាយជាការចូលរួមក្នុងការកសាងសន្តិភាព និង ធ្វើឲ្យប្រជាពលរដ្ឋទទួលសុភមង្គល ។ ពួកបញ្ញវន្តទាំងនោះ ធ្វើការរិះគន់ចំពោះអ្នកកាន់ធម៌ចាស់ ដែលមិនបានយល់ដឹងអំពីព្រះត្រៃបិដក ហើយដែលចេះតែសូត្រធម៌តាមៗគ្នាជាភាសាបាលី និង សំស្ក្រឹត ដោយមិនយល់ដឹងពីខ្លឹមសារ ឬ ន័យពិតប្រាកដនៃពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គនោះឡើយ ។ ពួកគេចោទប្រកាន់ព្រះសង្ឃដែលចេះតែសូត្រមន្ត ប្រោះព្រំស្រោចទឹក ធ្វើយ័ន្ត និង គាថានោះថា ជាអ្នកប្រកាន់ធម៌ចាស់ ។ ក្នុងទសវត្សរ៍ឆ្នាំ ១៩៤០ គឺ ពួកព្រះសង្ឃធម៌ថ្មីនេះហើយ ដែលបាននាំគ្នាធ្វើបាតុកម្មប្រឆាំងនឹងបារាំង នៅតាមវិថីនានានៅទីក្រុងភ្នំពេញ ។ មិនត្រឹមតែប៉ុណ្ណោះទេ ព្រះសង្ឃទាំងនោះ ក៏បានធ្វើការទាមទារឲ្យមានសិទ្ធិសេរីភាពជូនប្រជាពលរដ្ឋដែរ ។ ដោយសារមានភាពផ្ទុយគ្នាពីលក្ខណៈអភិរក្សនេះហើយ ទើបបាតុកម្មទាំងប៉ុន្មានរបស់ព្រះសង្ឃទាំងនោះ ហាក់ដូចជាធ្វើឲ្យមានការប៉ះពាល់ដល់ព្រះរាជបល្ល័ង្គ ដែលជាបង្អែកមួយនៃព្រះពុទ្ធសាសនារបស់ខ្មែរ ។ បញ្ញវន្តប្រភេទនេះ មួយចំនួនធំបិតនៅជាប់ក្នុងរង្វង់អ្នកជាតិនិយមដូចជា៖ ព្រះគ្រូអាចារ្យ ហែម ចៀវ ព្រះភិក្ខុប៉ាង ខាត់ ព្រះភិក្ខុ ខៀវ ជុំ ជាដើម ឯមួយចំនួនទៀត ដើរតាមពួកកុម្មុយនីស្តដូចជាអាចារ្យ មៀន ជាដើម ។

បញ្ញវន្តប្រភេទទីពីរគឺ ជាបញ្ញវន្ត ដែលបានសិក្សានៅរាជធានីភ្នំពេញ ឬ នៅបរទេស ជាពិសេស នៅប្រទេសបារាំង ។ បញ្ញវន្ត ដែលបានរៀនសូត្រនៅបរទេសនោះ មួយចំនួនជាសមាជិកព្រះរាជវង្សានុវង្ស មួយចំនួនជាកូនចៅរបស់មន្ត្រីធំៗ និង កូនចៅគហបតី ឬ កូនអ្នកមាន ។ ចំណែកឯបញ្ញវន្តមួយចំនួនទៀត ជាបញ្ញ

វន្តចេញពីរាស្ត្រសាមញ្ញធម្មតា ។ ក្រុមដែលមានដើមកំណើតចេញពីរាស្ត្រសាមញ្ញធម្មតានោះ មិនមានទ្រព្យសម្បត្តិ ទៅធ្វើការសិក្សានៅបរទេសបានទេ ប្រសិនបើគ្មានការធ្វើពលីកម្មយ៉ាងធំធេងរបស់ឪពុកម្តាយ ឬ បើគ្មានអាហារូបករណ៍ពីរាជរដ្ឋាភិបាល ឬ ពីបរទេស ។ នៅក្នុងចំណោមបញ្ញវន្តប្រភេទទីពីរនេះគឺ មានក្រុមកូនស្តេច កូនចៅអ្នកធំ និង កូនអ្នកមានម្ខាង និង ម្ខាងទៀត ក្រុមកូនអ្នកក្រ ។

បញ្ញវន្តដែលចូលមកធ្វើនយោបាយ ក៏ព្រោះតែសកម្មភាពនយោបាយនោះអាចនាំពួកគេទៅកាន់តំណែងខ្ពស់ ឬ ក៏យ៉ាងហោចណាស់អាចនៅរក្សាឋានៈសង្គមរបស់ខ្លួនបាន ឬ ក៏គេធ្វើនយោបាយ ដោយសារជំនឿរបស់គេតែប៉ុណ្ណោះ ។ ពួកក្រុមកូនអ្នកធំ និង ក្រុមកូនអ្នកមាន ឋិតនៅក្នុងចំណោមក្រុមអភិរក្សនិយម ផ្ទុយទៅវិញ ក្រុមកូនអ្នកក្រ តែងមាននិន្នាការទៅរកសង្គមនិយម ។ ទាំងនេះ ក៏ព្រោះថាអ្នកទាំងនោះ ដែលមានឋានៈទន់ទាប នឹកគិតថាភាពទន់ទាបរបស់ខ្លួនក៏ដោយសារអំពើអយុត្តិធម៌ក្នុងសង្គម ។ កូនចៅអ្នកធំ កូនចៅអ្នកមាន គេមានប្រាក់កាសចាយវាយសម្បូណ៌សប្បាយហ៊ឺហា មានរបស់របរប្រើប្រាស់ល្អជាង មានជីវភាពធូរធារជាង ។ល។ ដូច្នេះ ក្រុមកូនអ្នកក្រភាគច្រើន ក្រោយពីបានជ្រួតជ្រាបដោយមនោគមវិជ្ជាសង្គមនិយមផង យល់ឃើញថាដោយសង្គមមានភាពអយុត្តិធម៌ ពួកគេត្រូវតែតាំងចិត្តប្តេជ្ញាធ្វើការតស៊ូ ដើម្បីឲ្យមានយុត្តិធម៌ក្នុងសង្គម ហើយក៏ប្រកាន់យកមាគ៌ាម៉ាក្សនិយម ដើម្បីធ្វើការប្រយុទ្ធប្រឆាំងនឹងអយុត្តិធម៌សង្គមនោះ ។

សម្តេច សីហនុ តែងមានព្រះបន្ទូលជាញឹកញាប់ថា "ក្នុងសម័យសង្គមរាស្ត្រនិយម និស្សិតខ្មែរយើង ដែលបានទៅរៀននៅប្រទេសបារាំង នៅពេលត្រឡប់មកប្រទេសខ្មែរវិញច្រើនតែក្លាយទៅជាជនកុម្មុយនីស្ត ។ ចំណែកឯនិស្សិត ដែលបញ្ជូនឲ្យទៅរៀននៅសហភាពសូវៀត នៅពេលត្រឡប់មកវិញ ច្រើនតែក្លាយទៅជាជនមូលធននិយម" ។ ទាំងនេះ ក៏ជាការពិតមួយដែរ ព្រោះនៅពេលដែលនិស្សិត

មានធនធានតិចតួច ត្រូវបានបញ្ជូនឲ្យទៅរៀននៅប្រទេសបារាំង បានឃើញភាពសម្បូណ៌សប្បាយ ដែលខ្លួនមិនអាចឈោងទៅដល់ និង ម្យ៉ាងទៀត ដោយត្រូវទទួលបានការឃោសនាអប់រំមនោគមវិជ្ជាពីបញ្ញវន្តឆ្វេងនិយមរបស់បារាំងផង ក៏វាយតម្លៃស្ថានភាពនោះជាអយុត្តិធម៌ក្នុងសង្គម ។ អ្នកដឹកនាំខ្មែរក្រហមជាច្រើននាក់ឋិតនៅក្នុងក្រុមបញ្ញវន្តបែបនេះ ។ ផ្ទុយទៅវិញ អ្នកដែលបានទៅរៀននៅទីក្រុងម៉ូស្គូ បានឃើញដោយផ្ទាល់ភ្នែកនូវអ្វីដែលហៅថាកុម្មុយនីស្ត ។ ពួកក្រុមនោះមើលឃើញថា នៅក្នុងរបបកុម្មុយនីស្ត ពួកគេនឹងបាត់បង់អស់នូវសេរីភាព និង សិទ្ធិរបស់បុគ្គល ។ ក្នុងចំណោមបញ្ញវន្តឆ្វេងនិយមទាំងឡាយ ភាគច្រើនជាគ្រូបង្រៀន ឬ សាស្ត្រាចារ្យដែលមានឥទ្ធិពលយ៉ាងធំធេងទៅលើយុវជន ។ ពួកគេចេះធ្វើការទាក់ទាញយុវជនខ្មែរឲ្យដើរតាមគេ និង ធ្វើការលើកកំពស់មេដឹកនាំធំៗរបស់គេ ដែលភាគច្រើនត្រូវបានទទួលស្គាល់ថាជាអ្នកដឹកនាំស្អាតស្អំ និង មានការចេះដឹងខ្ពស់ ។ ពួកបញ្ញវន្តទាំងនោះ ផ្តល់ការគាំទ្រដ៏រឹងមាំ និង យ៉ាងថ្លៃថ្លាចំពោះខ្មែរក្រហមក្នុងការតស៊ូរបស់ពួកគេ ដើម្បីឡើងកាន់អំណាចនៅក្នុងប្រទេសខ្មែរ ។

## ខ្ញុំធ្វើកុម្ម៉ង់ដូ

នៅក្នុងសម័យសង្គ្រាមនោះ បន្ទាប់ពីរដ្ឋប្រហារ រដ្ឋាភិបាលលោក លន់ នល់ បានចេញបញ្ជាឲ្យមន្ត្រីអ្នករដ្ឋការផ្នែកស៊ីវិលទាំងអស់ ចូលបំរើការងារក្នុងកងកុម្ម៉ង់ដូ ។ នាយទាហានជាច្រើនរូប បានត្រូវចាត់ទៅតាមក្រសួង ឬ មន្ទីរនានា ដើម្បីធ្វើការហ្វឹកហ្វឺនដល់មន្ត្រីអ្នករដ្ឋការស៊ីវិលនូវមុខវិជ្ជាបាញ់កាំភ្លើង និង ចំណេះដឹងផ្នែកប្រយុទ្ធផ្សេងៗ ។ ភារកិច្ចសំខាន់ៗរបស់ក្រុមកុម្ម៉ង់ដូ មានដូចជាយាមការពារអាគារសាធារណៈទាំងថ្ងៃ ទាំងយប់ និង ជួយផ្តល់ការគាំទ្រផ្នែកភស្តុភារចំពោះកងទ័ពនៅពេលត្រូវការ ។ ក្នុងឋានៈជាបុគ្គលិករបស់ក្រុមហ៊ុនរដ្ឋ ខ្ញុំក៏ត្រូវទទួលការ

កិច្ចក្នុងកងកុម្ម៉ង់ដូដូចជាមន្ត្រីរដ្ឋការទូទៅដែរ ។ ខ្ញុំត្រូវទទួលការហ្វឹកហ្វឺនផ្នែកការពារខ្លួន វិន័យយោធា និង បច្ចេកទេសបាញ់កាំភ្លើងដែរ ។ ក៏ប៉ុន្តែ ខ្ញុំមិនបានចូលទៅហ្វឹកហ្វឺនឲ្យបានទៀងទាត់ទេ ព្រោះខ្ញុំមិនសូវចូលចិត្តហាត់រៀនមុខវិជ្ជាទាំងនោះ ។ ដូច្នេះ ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនបានចេញលិខិតព្រមាន ហាក់បីដូចជាស្តីបន្ទោសថា ខ្ញុំមិនមែនជាអ្នកស្រឡាញ់ជាតិយ៉ាងដូច្នោះដែរ ។

ក្នុងឋានៈជាសមាជិកកងកុម្ម៉ង់ដូ ខ្ញុំមានភារកិច្ចធ្វើការយាមកាមតាមច្រកចេញចូលនៃអាគាររបស់ក្រុមហ៊ុនសុរាគារខ្មែរ អស់រយៈពេលជាច្រើនម៉ោងក្នុងមួយថ្ងៃ នៅពេលថ្ងៃ ។ នៅពេលយប់ពួកយើងត្រូវចាត់ឲ្យទៅយាមភូមិគ្រឹះរបស់លោកប្រធានអគ្គនាយក ។ នៅពេលយាមនោះ ពួកយើងកាន់កាំភ្លើងម៉ាកការ៉ាប៊ីន A1 របស់បារាំង ក្រោយមកដោយសារមានជំនួយពីសហរដ្ឋអាមេរិក គេដូរកាំភ្លើងការ៉ាប៊ីន មកកាំភ្លើងM16 វិញ ។ លោកប្រធានអគ្គនាយកជាមនុស្សមានចិត្តសប្បុរស ។ រាល់យប់ គាត់តែងរៀបចំម្ហូបអាហារ និង តែទឹកកកទុកឲ្យយើងជានិច្ចមុននឹងយើងចាប់ផ្តើមធ្វើការងាររបស់យើង ។ យើងមិនដែលឃើញគាត់ផ្ទាល់ ឬ សមាជិកណាម្នាក់របស់គ្រួសារគាត់ឡើយ ។ ព្រោះពួកយើងត្រូវចាត់ឲ្យទៅឈរយាម នៅលើដំបូលភូមិគ្រឹះរបស់គាត់ ។ លោកប្រធានអគ្គនាយករបស់ខ្ញុំនោះ ជាមន្ត្រីគយ និង រដ្ឋាករ ដែលមានឋានៈជាអធិការគយ ។ មុខតំណែងគយ ជាមុខតំណែងដែលអាចរកប្រាក់ចំណូលបានយ៉ាងស្រួល ធ្វើឲ្យជីវភាពរបស់ពួកគាត់មានការធូរធារយ៉ាងខ្លាំង ។ ភរិយារបស់គាត់ជាស្ត្រីម្នាក់ដែលមានឈ្មោះល្បី ធ្លាប់កាន់តំណែងជារដ្ឋលេខាធិការក្រសួងឃោសនាការពីឆ្នាំ ១៩៦៧ ដល់ ១៩៦៩ ក្នុងសម័យសង្គមរាស្ត្រនិយម ។

លោកស្រី ជិន រ៉ែន ដែលជាភរិយារបស់លោកប្រធានអគ្គនាយកនោះជាស្ត្រីដ៏កម្រដែលបានឡើងកាន់តំណែងរហូតដល់ថ្នាក់រដ្ឋមន្ត្រី ។ លោកប្រធានអគ្គនា

យក ជិន រ៉ែន ត្រូវបានចាត់ឲ្យមកកាន់តំណែង ជាប្រធានអគ្គនាយកក្រុមហ៊ុនសុរាគារខ្មែរនេះ បន្ទាប់ពីលោក ភួង ម៉ារហ្គាំង ដែលជាអ្នកជំនួយការជិតស្និទ្ធម្នាក់របស់សម្តេច សីហនុ បានត្រូវចោទប្រកាន់ថា បានលួចប្រាក់របស់ក្រុមហ៊ុន ហើយត្រូវផ្តន្ទាទោសជាប់គុកជាច្រើនឆ្នាំ ។ នៅរាល់ពេលដែលខ្ញុំឈរយាមនៅលើដំបូលផ្ទះរបស់លោកប្រធាននោះ ខ្ញុំមានអារម្មណ៍រាយមាយ ដោយចេះតែនឹកបារម្ភចំពោះអនាគតរបស់ខ្ញុំ ដែលកំពុងជួបប្រទះនូវឧបសគ្គដ៏ធំ ដោយសារតែរដ្ឋប្រហារយោធានោះ ។

ប្រជាពលរដ្ឋក្នុងទីក្រុងភ្នំពេញ ហាក់ដូចជាចេះបត់បែនតាមជីវភាពប្រចាំថ្ងៃ និង ភាពជាក់ស្តែងនៃសភាពការណ៍នយោបាយរបស់ប្រទេស ។ អ្នកនៅទីក្រុងទាំងនោះ នាំគ្នាផ្អើលស្លៀកពាក់ឯកសណ្ឋានយោធា ដែលឯកសណ្ឋានទាំងនោះបានក្លាយជាម៉ូតសំលៀកបំពាក់របស់ពួកគេ ។ សមាជិកកុម្ម៉ង់ដូធម្មតា ស្លៀកពាក់ឯកសណ្ឋានយោធា តែគ្មានពាក់សញ្ញាស័ក្តិយសអ្វីទេ ។ ក៏ប៉ុន្តែ មេកុម្ម៉ង់ដូស្លៀកពាក់ឯកសណ្ឋានយោធា ព្រមទាំងមានកាំភ្លើងខ្លី (Pistolet) នៅចង្កេះ ។ នៅសម័យនោះ នរណាដែលមានកាំភ្លើងខ្លី (Pistolet) នៅចង្កេះ បង្ហាញសញ្ញាថាអ្នកនោះជាមេ ។ ម្យ៉ាងទៀត នរណាដែលមានកាំភ្លើងខ្លីនៅនឹងចង្កេះ ក៏បញ្ចេញភាពសង្ហារផងដែរ ។

# អ្នកណាក៏អាចទិញសក្តិពាក់បានដែរ សម័យ លន់ នល់

មន្ត្រីអ្នករដ្ឋការមួយចំនួនសុំផ្ទេរទៅផ្នែកយោធា ហើយក៏ក្លាយទៅជាមេទាហាន ។ ក៏ប៉ុន្តែសម័យនោះ នៅក្នុងជួរកងទ័ពលោក លន់ នល់ កើតមានអំពីពុករលួយយ៉ាងធាប់រហ័សរហូតដល់ថ្នាក់ ដែលគេអាចទិញស័ក្តិយកមកពាក់បាន ។ ដូច្នេះហើយ កងទ័ពរបស់លោក លន់ នល់ កាន់តែកើនចំនួនឡើងឥតឈប់ឈរ

រួមផ្សំដោយបុគ្គលិកស៊ីវិល ដែលផ្ទេរមកពីគ្រប់ផ្នែក ដូចជាអ្នករដ្ឋការស៊ីវិលធម្មតា គ្រូបង្រៀន បូកផ្សំជាមួយអ្នកជំនួញ ជាងឈើ ជាងដែក ចិនកាប់ជ្រូក ជាងកាត់សក់ សិល្បករ សិល្បការិនី អ្នកលេងល្ខោន អ្នកលេងកុន អ្នកចំរៀង អ្នកច្រៀងអាយ៉ៃ ។ល។ និង មនុស្សមួយចំនួនដែលយល់ថាកងទ័ពជាកន្លែងដែលគេអាចរកលុយបាន អាចធ្វើជាអ្នកមាន នៅក្នុងសម័យសង្គ្រាម ។ មិត្តរបស់ខ្ញុំម្នាក់ដែលធ្លាប់រៀននៅមហាវិទ្យាល័យឈ្មោះ មន្ថា បានចូលទៅបំរើកងទ័ពមានឋានៈជាអនុសេនីយទោ ចាប់ពីឆ្នាំដំបូងនៃសង្គ្រាម ។ មន្ថា បានត្រូវបាត់ខ្លួនតាំងពីពេលនោះរហូតមក ។ ខ្ញុំឮគេថា មន្ថា បានស្លាប់នៅពេលប្រយុទ្ធលើកទីមួយ នៅឯកំពង់សិលា មួយឆ្នាំបន្ទាប់មក ។

នៅពេលចេញពីក្រុមហ៊ុនសុរាគារខ្មែរ (S K D) ខ្ញុំសង្កេតឃើញថា បន្ទុកនៃសង្គ្រាមដែលត្រូវរែកពុនទាំងអស់គ្នានោះ មិនបានត្រូវចែករំលែកឲ្យបានដល់ពលរដ្ឋគ្រប់ៗគ្នាឡើយ ជាពិសេសពលរដ្ឋដែលរកស៊ីចិញ្ចឹមជីវិតនៅក្នុងវិស័យឯកជន ។ នៅក្នុងក្រុមហ៊ុនសូគីឡេ និង កូមិន្នខ្មែរ បុគ្គលិកទាំងអស់មិនបានត្រូវចាប់បង្ខំឲ្យទៅធ្វើការយាមកាមដូចមន្ត្រីអ្នករដ្ឋការទេ ។ ក្រុមហ៊ុនឯកជនទាំងនោះ គេជួលទាហានឲ្យមកយាមអាគារ ដើម្បីទុកឱកាសឲ្យបុគ្គលិករបស់គេ គិតគូរតែពីការខិតខំបំពេញការងាររបស់ក្រុមហ៊ុនតែប៉ុណ្ណោះ ។

## សម្ព័ន្ធភាព លន់ នល់ បែកគ្នាជាបក្សផ្សេងៗ

មួយឆ្នាំបន្ទាប់ពីបានកាន់អំណាចមក របប លន់ នល់ កាន់តែបាត់បង់ទៅៗនូវការគាំទ្រពីប្រជាពលរដ្ឋ និង ទីតាំងទឹកដីរបស់ខ្លួន ធ្វើឲ្យតំបន់ដែលរបបនេះកាន់កាប់កាន់តែរួញតូចទៅៗ ។ នៅខែ មីនា ១៩៧១ រណសិរ្សរបស់សម្តេច សីហនុ ដែលឋិតនៅក្រោមអំណាចរបស់ខ្មែរក្រហម បានប្រកាសថាពួកគេបានកាន់កាប់

ទឹកដីបួនភាគប្រាំនៃប្រទេសកម្ពុជារួចទៅហើយ ។ ជម្លោះរវាងភាគីដែលធ្លាប់បានរួបរួមគ្នាធ្វើការវាយរំលំរបបសម្តេច សីហនុ នោះ ក៏កាន់តែលេចធ្លោឡើងជាសាធារណៈ ។ នៅថ្ងៃទី ៩ តុលា ១៩៧០ លោក លន់ នល់ បានប្រកាសបង្កើតសាធារណរដ្ឋខ្មែរ ។ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ បានប្តេជ្ញាបោះបង់ចោលនូវឋានៈ និង បុព្វសិទ្ធិជាស្តេច ដើម្បីមកធ្វើជាពលរដ្ឋសាមញ្ញវិញ។ បន្ទាប់មក អ្នកអង្គម្ចាស់ សិរីមតៈ ក៏បង្កើតគណបក្សមួយឈ្មោះថា គណបក្សសាធារណរដ្ឋខ្មែរ ។ ចំណែកឯលោក អ៊ិន តាំ ដែលជាប្រធានរដ្ឋសភាស្តីទី បានធ្វើការប្រមែប្រមូលអ្នកប្រជាធិបតេយ្យទាំងឡាយ និង ធ្វើឲ្យមានដំណើរការឡើងវិញនូវគណបក្សប្រជាធិបតេយ្យ ដែលត្រូវបានបង្កើតនៅទសវត្សរ៍ឆ្នាំ ១៩៤០ ដោយអ្នកនយោបាយដ៏ល្បីៗទាំងឡាយ ដែលធ្វើឲ្យប្រសូតឡើងនូវរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៤៧ ។

លោក អ៊ិន តាំ ឡើងកាន់តំណែងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃនៅខែ ធ្នូ ១៩៦៤ បន្ទាប់ពីគាត់បង្កលក្ខណៈឲ្យចាប់ខ្លួននូវខ្មែរសេរីពីរនាក់ ដែលជាភ្នាក់ងាររបស់លោក សឺង ង៉ុកថាញ់ ។ ក្នុងចំណោមខ្មែរសេរីពីរនាក់នោះ មានម្នាក់ឈ្មោះ ព្រាប អ៊ិន ដែលត្រូវជាសាច់ញាតិរបស់គាត់ផង ។ នៅឆ្នាំ ១៩៦៤ នោះ លោក ព្រាប អ៊ិន បានត្រូវគេនាំមកបង្ហាញខ្លួននៅចំពោះអង្គសមាជពិសេសមួយ នៅក្នុងក្រុងភ្នំពេញ ហើយត្រូវបានតុលាការសឹកកាត់ទោសប្រហារជីវិត ។ លោក ព្រាប អ៊ិន បានត្រូវគេនាំយកទៅបាញ់ចោលនៅត្រពាំងក្រឡឹង ក្នុងខេត្តកំពង់ស្ពឺ ។ ការបាញ់សម្លាប់នោះ បានត្រូវថតជាឯកសារដែលក្រសួងឃោសនាការសម័យនោះ យកទៅបញ្ចាំងផ្សព្វផ្សាយគ្រប់ទីកន្លែង នៅក្នុងប្រទេសកម្ពុជា ។

លោក អ៊ិន តាំ មានសំដីថ្វីមាត់ពូកែនិយាយតាមរបៀបព្រោកប្រាជ្ញលេបខាយរបស់គាត់ ។ រាល់ៗដង នៅពេលដែលគាត់និយាយជាសាធារណៈ គាត់តែង

តែរំលឹកអំពីសេចក្តីស្រឡាញ់របស់គាត់ចំពោះស្រុកខ្មែរ ប្រពៃណីខ្មែរ សិល្បៈខ្មែរ ជាពិសេស ភ្លេងខ្មែរ ។ រហូតដល់ថ្ងៃ គាត់ចូលរួមទម្លាក់សម្តេច សីហនុ ពីតំណែងប្រមុខរដ្ឋ លោក អ៊ិន តាំ តែងតែថ្លែងជាសាធារណៈ នូវសេចក្តីស្វាមីភក្តិរបស់គាត់ចំពោះអង្គសម្តេច ។ នៅពេលដែលគេទំលាក់សម្តេច សីហនុ ពីតំណែងនោះ លោក អ៊ិន តាំ មានមុខនាទីជាប្រធានរដ្ឋសភាស្តីទី ដោយហេតុថា លោក ចេង ហេង ដែលជាប្រធានរដ្ឋសភាពេញសិទ្ធិនោះ ត្រូវឡើងកាន់តំណែងជាប្រមុខរដ្ឋស្តីទីនៅពេលអវត្តមានរបស់សម្តេច សីហនុ ។ បន្ទាប់ពីរដ្ឋប្រហារមកលោក អ៊ិន តាំ បានក្លាយទៅជាអ្នកប្រឆាំងសម្តេច សីហនុ យ៉ាងស្លាប់រស់ និង ប្រកាសថាជាអ្នកលបលួចស្រឡាញ់ និង គាំទ្រលោក លន់ នល់ ជាយូរមកហើយ ។

ចាប់ពីពេលនោះមក គាត់បាននិយាយជាសាធារណៈថា៖ "ជាច្រើនឆ្នាំមកហើយ ខ្ញុំលួចស្រឡាញ់លោក លន់ នល់ ព្រោះលោកជាអ្នកដឹកនាំខ្មែរដ៏ពិសេសមួយរូប" ។ ប៉ុន្តែអស់រយៈពេលមួយឆ្នាំ បន្ទាប់ពីរដ្ឋប្រហារមក លោក អ៊ិន តាំ បានផ្លាស់ប្តូរចិត្តគំនិតមកធ្វើជាអ្នកប្រឆាំងរបបលោក លន់ នល់ យ៉ាងចេញមុខក្នុងឋានៈជាប្រធានគណបក្សប្រឆាំងឈ្មោះ "គណបក្សប្រជាធិបតេយ្យ" ។

## រដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ និង គណបក្សប្រជាធិបតេយ្យ

គណបក្សប្រជាធិបតេយ្យ បានត្រូវបង្កើតឡើងនៅឆ្នាំ ១៩៤៦ ដោយបញ្ញវន្តដ៏ឆ្នើមៗមួយចំនួន ដែលមានគំនិតចង់នាំលទ្ធិប្រជាធិបតេយ្យមកក្នុងប្រទេសកម្ពុជា និង ចង់បានឯករាជភាពពីបារាំង។ បញ្ញវន្តទាំងនោះ ដែលធ្លាប់បានទៅរៀននៅប្រទេសបារាំង មានជាអាទិ៍៖ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស លោក អៀវ កើស លោក ស៊ឹម វ៉ា លោក ឈាន វ៉ម និង លោក ថុន អ៊ុក ។ លើកលែងតែព្រះអង្គម្ចាស់ យុត្តិវង្ស និង លោក អៀវ កើស ចេញ ខ្ញុំសុទ្ធតែបានធ្វើការផ្ទាល់ជាមួយនឹងរជន

ទាំងអស់នោះ ។ ជាពិសេស លោក ឈាន វ៉ម លោក ស៊ឹម វ៉ា និង លោក ចុន អ៊ុក នៅក្នុងជួរណេសិរ្សមួយ ដែលដឹកនាំដោយអ្នកនយោបាយជើងចាស់ម្នាក់ទៀតគឺ លោក សឺន សាន ។ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ជាកូនខ្មែរដ៏កម្ររក បានមួយរូប ព្រោះព្រះអង្គបានសិក្សានៅប្រទេសបារាំង រហូតទទួលបានសញ្ញាប័ត្រ ថ្នាក់បណ្ឌិតផ្នែកគណិតសាស្ត្រ ។ ព្រះអង្គម្ចាស់អង្គនេះ មានការចេះដឹងជ្រៅជ្រះ ណាស់ ។ តាមសៀវភៅប្រវត្តិសាស្ត្រ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ទ្រង់សុគត ក្នុងព្រះជន្មយ៉ាងក្មេងគឺ ៣៤ ព្រះវស្សា ក្រោមទំងន់នៃការងារ និង ដោយសារជំងឺ របេង និង គ្រុនចាញ់នៅឆ្នាំ ១៩៤៧ ។ លោក អៀវ កើស បានត្រូវគេសំលាប់នៅ ខែ មករា ១៩៥០ ។ វរជនទាំងពីររូបនេះ សុទ្ធតែជាអ្នកចូលរួមបង្កើតនូវរដ្ឋធម្មនុញ្ញ ទីមួយនៃព្រះរាជាណាចក្រកម្ពុជាយើង ដែលបានទទួលស្គាល់សិទ្ធិសំខាន់ៗរបស់ ពលរដ្ឋ និង ដែលបានសាងខឿននៃរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ រដ្ឋធម្មនុញ្ញទីមួយនេះ បានត្រូវអនុម័តដោយរដ្ឋសភា ដែលជ្រើសតាំងឡើងតាមរយៈការ បោះឆ្នោតសកលរបស់ពលរដ្ឋភេទប្រុសទាំងអស់ ។ នៅសម័យនោះ ពលរដ្ឋខ្មែរ ភេទស្រី មិនទាន់មានសិទ្ធិចូលរួមក្នុងការបោះឆ្នោតនៅឡើយទេ ។ ការបោះឆ្នោត បានធ្វើឡើងនៅសម័យអាណាព្យាបាល (Protectorat) បារាំងដោយអនុវត្តតាម កិច្ចព្រមព្រៀងបណ្ដោះអាសន្ន (Modus Vivendi) ដែលចុះហត្ថលេខានៅថ្ងៃ ៧ មករា ១៩៤៦ បន្ទាប់ពីបារាំងបានវិលមកត្រួតត្រាប្រទេសកម្ពុជាវិញ ក្រោយ សង្គ្រាមលោកលើកទី២ ។ ក្នុងកិច្ចព្រមព្រៀងនោះ បារាំងបានទទួលស្គាល់ស្វ័យ ភាពនៃព្រះរាជាខ្មែរក្នុងការគ្រប់គ្រងផ្ទៃក្នុងៗប្រទេស ដែលអនុញ្ញាតឲ្យមានការ បង្កើតគណបក្សនយោបាយ ឲ្យមានសេរីភាពខាងការសំដែងមតិ សេរីភាពក្នុងការ ចូលរួមប្រជុំ ព្រមទាំងសេរីភាពស៊ីវិលផ្សេងៗទៀត ។

ការបោះឆ្នោតលើកទី១ បានប្រព្រឹត្តទៅនៅខែ កញ្ញា ១៩៤៦ ។ គណបក្ស

ប្រជាធិបតេយ្យ ទទួលបានជោគជ័យគឺ បានទទួល ៥០ កៅអីលើកៅអីចំនួន ៦៩ ។ ដោយសារជោគជ័យនៃការបោះឆ្នោតនេះ គណបក្សប្រជាធិបតេយ្យបានបង្កើតរដ្ឋាភិបាលមួយដែលមានព្រះអង្គម្ចាស់ យុត្តិវង្ស ជានាយករដ្ឋមន្ត្រី ។ អាណត្តិរបស់រដ្ឋាភិបាលនេះ រួមមានទាំងការព្រាង និង អនុម័តឲ្យប្រើប្រាស់នូវរដ្ឋធម្មនុញ្ញថ្មីដែលត្រូវប្រកាសឲ្យប្រើជាផ្លូវការនៅថ្ងៃទី ១៦ ឧសភា ១៩៤៧ ដោយព្រះករុណាព្រះបាទ នរោត្តម សីហនុ ។ ក៏ប៉ុន្តែ នៅក្នុងរដ្ឋធម្មនុញ្ញនោះ មានបទបញ្ញត្តិមួយចំនួន បានអនុញ្ញាតឲ្យព្រះមហាក្សត្រចូលជ្រៀតជ្រែក ក្នុងកិច្ចការរបស់រដ្ឋាភិបាល ។ រដ្ឋធម្មនុញ្ញសម័យនោះ បានចែងថាអំណាចនីតិប្រតិបត្តិ នីតិបញ្ញត្តិ និងអំណាចតុលាការទាំងឡាយ ចេញមកពីព្រះមហាក្សត្រ ជាហេតុឲ្យព្រះអង្គមានអំណាចរុះរើរដ្ឋាភិបាល និង រំលាយរដ្ឋសភាបាន ទោះបីជារដ្ឋសភានោះបានត្រូវប្រជាពលរដ្ឋបោះឆ្នោតឲ្យក៏ដោយ ។

ចាប់តាំងពីឆ្នាំ ១៩៤៦ រៀងមក គណបក្សប្រជាធិបតេយ្យបានទទួលជ័យជំនះជាប់ជានិច្ច ក៏ប៉ុន្តែនៅអាណត្តិនីមួយៗ គណបក្សនេះមិនបានកាន់អំណាចឲ្យគ្រប់អាយុកាលនៃអាណត្តិទេ ដោយសារព្រះមហាក្សត្រព្រះបាទ នរោត្តម សីហនុ ចេះតែមានហេតុផល រំលាយរដ្ឋសភារបស់គណបក្សប្រជាធិបតេយ្យនេះជានិច្ច ដើម្បីព្រះអង្គក្តាប់ស្ថានការណ៍នយោបាយ ឲ្យស្ថិតនៅក្នុងកណ្តាប់ព្រះហស្តព្រះអង្គបាន ។ ដូច្នេះគណបក្សប្រជាធិបតេយ្យក៏ចេះតែឈ្នះឆ្នោតជាដរាបរហូតដល់ថ្ងៃដែលព្រះមហាក្សត្រទ្រង់សម្រេចព្រះទ័យ ដាក់រាជសម្បត្តិថ្វាយព្រះវររាជបិតារបស់ព្រះអង្គហើយទ្រង់យាងចូលប្រឡូកក្នុងឆាកនយោបាយដោយផ្ទាល់ព្រះអង្គ ។ នៅឆ្នាំ ១៩៥៥ ព្រះអង្គបានបង្កើតចលនាសង្គមរាស្ត្រនិយម ។ ចាប់តាំងពីពេលនោះប្រទេសកម្ពុជាយើង បានស្ថិតនៅក្រោមរបបគ្រប់គ្រងមួយដែលមានលក្ខណៈជារបបនៃបក្សតែមួយ ដោយគណបក្សប្រជាធិបតេយ្យ ត្រូវនៅសម្ងំស្ងៀមក្នុងភាព

អសកម្មរហូតដល់ឆ្នាំ ១៩៧១ ។

បន្ថែមលើរណសិរ្សយោធា លោក លន់ នល់ បានបើករណសិរ្សប្រយុទ្ធលើវិស័យជាច្រើនទៀត ដូចជាការធ្វើឲ្យមានភាពបរិសុទ្ធនៃជាតិសាសន៍ខ្មែរដែលគេ ឲ្យឈ្មោះថា "ខ្មែរមន" ដោយមានវិធីសាស្ត្រយកព្រះពុទ្ធសាសនាទៅតទល់ប្រឆាំងលទ្ធិកុម្មុយនីស្ត និង យកគំនិតបដិវត្តន៍សម័យថ្មីគឺ បដិវត្តន៍សាធារណរដ្ឋ ប្រឆាំងរបបរាជានិយម ដោយសង្ឃឹមថាអាចនឹងរក្សាបាននូវការគាំទ្រពីប្រជាពលរដ្ឋចំពោះរបបរបស់គាត់ ។ ហេតុដូច្នេះហើយទើបគេអនុញ្ញាតឲ្យមានការបង្កើតគណបក្សនយោបាយជាច្រើន ។ ប្អូនប្រុសលោក លន់ នល់ ឈ្មោះ លន់ ណុន បានបង្កើតគណបក្សនយោបាយមួយឈ្មោះ គណបក្សសង្គមសាធារណរដ្ឋដែលប្រមូលផ្តុំអ្នកគាំទ្រលោក លន់ នល់ ទាំងអស់ និង ជាគណបក្សប្រណាំងប្រជែងជាមួយក្រុមអ្នកកាន់អំណាចមួយទៀតគឺ គណបក្សសាធារណរដ្ឋរបស់អតីតអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីមតៈ ។ ចំណែកឯគណបក្សប្រជាធិបតេយ្យ ក៏មានសកម្មភាពឡើងវិញនៅក្នុងឆាកនយោបាយថ្មីនៃប្រទេសកម្ពុជាយើងដែរ ដោយបន្តប្រកាន់យករូបសញ្ញាចាស់ ដែលមានសញ្ញាក្បាលដំរីកាន់ផ្កាឈូកបី ។ គណបក្សនេះ ទាក់ទាញបាននិស្សិត និង បញ្ញវន្ត ហើយដើតួនាទីជាគណបក្សប្រឆាំង ។ នៅក្នុងចំណោមថ្នាក់ដឹកនាំនៃគណបក្ស គេសង្កេតឃើញមានវរជនល្បីៗពីររូបគឺ លោក ចៅ សៅ និង លោក ឌុក រ៉ាស៊ី បន្ថែមលើវរជនពូកែខាងថ្វីសំដីមួយរូបទៀតគឺ លោក អ៊ិន តាំ ។

លោក ឌុក រ៉ាស៊ី មានឈ្មោះថាជាអ្នកនយោបាយស្តាំនិយម ដែលសម្តេច សីហនុ លាបពណ៌ថា"ខ្មែរខៀវ" ។ គាត់ធ្លាប់បានកាន់តំណែងជាអនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌នៅខែ តុលា ១៩៥៨ អស់រយៈពេលប្រាំមួយខែ និង ជារដ្ឋលេខាធិការក្រសួងផែនការ ក្នុងរយៈពេលប្រាំមួយខែទៀត ចាប់ពីខែ តុលា ១៩៦៦ ។

លោក ឌុក រ៉ាស៊ី ក៏ជាអ្នកតំណាងរាស្ត្រអស់រយៈពេលជាច្រើនឆ្នាំទៀតផង ។ ក្រៅពីនោះ គាត់បានបង្កើតកាសែតមួយឈ្មោះថា "ភ្នំពេញប្រេស" "Phnom Penh Presse" ចេញផ្សាយនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ និង ១៩៦០ ។ នៅក្នុងពេលដែលគណបក្សប្រជាធិបតេយ្យធ្វើសកម្មភាពឡើងវិញនៅឆ្នាំ ១៩៧១ នោះ លោក ឌុក រ៉ាស៊ី នៅធ្វើជាសាស្ត្រចារ្យច្បាប់ បង្រៀននៅមហាវិទ្យាល័យច្បាប់ ។

លោក ថៅ សៅ ក៏ជាសាស្ត្រចារ្យបង្រៀននៅមហាវិទ្យាល័យច្បាប់ម្នាក់ទៀតដែរ ។ ក៏ប៉ុន្តែ គាត់ជាអ្នកនយោបាយប្រភេទមួយទៀត ដែលផ្ទុយពីលោក ឌុក រ៉ាស៊ី ។ លោក ថៅ សៅ មាននិន្នាការទោរទន់ទៅរកសង្គមនិយម ដែលសម្តេច នរោត្តម សីហនុ បានលាបពណ៌ថាជាពួកខ្មែរ "ស៊ីជម្ពូ"[49] ។ លោក ថៅ សៅ មានការគោរពរាប់អានខ្លាំងពីមជ្ឈដ្ឋានទូទៅ ដោយសារភាពស្អាតស្អំមិនពុករលួយរបស់គាត់ ។ លោក ថៅ សៅ ធ្លាប់កាន់តំណែងជា អនុរដ្ឋលេខាធិការ រដ្ឋលេខាធិការ ក្រសួងហិរញ្ញវត្ថុ ក្រសួងផែនការ ចាប់ពីឆ្នាំ ១៩៦២ រហូតដល់ខែ តុលា ១៩៦៦ នៅក្នុងរដ្ឋាភិបាលមួយ ដែលមានស្នេហភាពជាងគេដែលមានព្រះអង្គម្ចាស់ នរោត្តម កន្តុល ជានាយករដ្ឋមន្ត្រី ។ លោក ថៅ សៅ ជាអ្នកនយោបាយខ្មែរមួយរូបដ៏កម្រ ដែលមិនប្រកាន់ខ្លួនគឺ ស្លៀកពាក់សាមញ្ញបំផុតនៅក្រៅម៉ោងធ្វើការ ។ គាត់ពាក់ស្បែកជើងផ្ទាត់ បើករថយន្តធុន 2CW ទៅទទួលទានគុយទាវតាមចិញ្ចើមថ្នល់ ។ នៅពេលគេសួរគាត់ហេតុអ្វីបានធ្វើយ៉ាងនេះ គាត់និយាយថានេះជាវិធីល្អណាស់ដើម្បីឲ្យស្គាល់ជីវភាពពិតប្រាកដរបស់ប្រជាពលរដ្ឋ ។ ជាទូទៅ អ្នកស្រុកមួយចំនួនធំ តែងរិះគន់មន្ត្រីធំៗថ្នាក់រដ្ឋមន្ត្រីជាដើមថារស់នៅខ្ពស់ពេក នៅដាច់ឆ្ងាយពីប្រជាពលរដ្ឋ រហូតមិនដឹងអង្ករមួយគីឡូក្រាមថ្លៃប៉ុន្មាន ឬ គុយទាវមួយចានថ្លៃប៉ុន្មានជា

---

[49] ក្រៅពីពួកខ្មែរខៀវ និង ខ្មែរក្រហម សម្តេច សីហនុ បានដាក់ឈ្មោះខ្មែរមួយក្រុមទៀតដែលមាននិន្នាការទៅឆ្វេងគឺ សង្គមនិយមដែរ តែមិនទាន់ដល់ថ្នាក់ក្រហមឆ្អិនឆ្អៅដូចខ្មែរក្រហមថា ជាពួកខ្មែរស៊ីជម្ពូ ។

ដើម ។ ដូច្នេះ លោក ចៅ សៅ ចាប់ផ្តើមធ្វើខុសគេ ។ គាត់មានដើមកំណើតនៅកម្ពុជាក្រោមគឺ នៅភូមិភាគខាងត្បូងនៃប្រទេសវៀតណាមបច្ចុប្បន្ន ។ ខ្មែរយើងអាចស្គាល់បងប្អូនទាំងនោះជាខ្មែរក្រោម ដោយសារឈ្មោះ និង សំនៀងភាសានិយាយរបស់ពួកគាត់ ។ នៅកម្ពុជាក្រោម គេដាក់នាមត្រកូលទៅតាមភូមិកំណើត ទោះបីជាម្នាក់ៗចេញមកពីគ្រួសារទីទៃពីគ្នាក៏ដោយ ។ តាមរយៈឈ្មោះរបស់ពួកគាត់ យើងអាចស្គាល់គ្រួសារគាត់ផង និង ភូមិរបស់ពួកគាត់ផង ។ ឈ្មោះនាមត្រកូលដែលគេប្រើច្រើនជាងគេគឺៈ ចៅ សឺន ឬ សឺង ទ្រឿង ថាច់ ដាញ់ និង គិម ជាដើម ។ បងប្អូនកម្ពុជាក្រោម ដែលមករស់នៅលើទឹកដីកម្ពុជាកណ្តាលយើងនេះ បង្កើតបានជាសហគមន៍ដ៏រឹងមាំមួយ ដែលចេះស្រឡាញ់គ្នា និង មានសាមគ្គីភាពរវាងគ្នា និង គ្នាយ៉ាងខ្លាំង ។ ដោយសារធ្លាប់ទទួលរងទុក្ខវេទនា ដោយការធ្វើទុក្ខបុកម្នេញរបស់ជនជាតិវៀតណាម មកលើរូបគេ ជាពិសេស នៅវៀតណាមខាងត្បូងនេះ បងប្អូនខ្មែរកម្ពុជាក្រោម មានស្មារតីស្នេហាជាតិយ៉ាងខ្ពស់ ហើយនិយមចូលប្រឡូកក្នុងឆាកនយោបាយយ៉ាងខ្លាំងក្លាបំផុត ។

ភ្លាមៗបន្ទាប់ពីគណបក្សប្រជាធិបតេយ្យ ចាប់ផ្តើមដំណើរការឡើងវិញនោះ បងប្រុសទី២របស់ខ្ញុំគឺ បងស៊ីនឿន ក៏ស្ម័គ្រចូលជាសមាជិកគណបក្សនេះ ដូចជានិស្សិតមួយចំនួននៅមហាវិទ្យាល័យច្បាប់ដែរ ។ បន្ទាប់មក គាត់ក៏ចាប់ឡើងឋានៈក្នុងជួរគណបក្សយ៉ាងឆាប់រហ័ស ។ បងប្រុសខ្ញុំមានទំនាក់ទំនងល្អណាស់ ជាមួយថ្នាក់ដឹកនាំគណបក្ស ។ នៅទីបំផុត បងខ្ញុំក៏អន្ទងខ្ញុំឲ្យចូលជាសមាជិកគណបក្សប្រជាធិបតេយ្យជាមួយគាត់ដែរ ។ នៅសម័យនោះ ខ្ញុំពុំមានការយល់ដឹងអំពីប្រវត្តិ ឬ គោលនយោបាយរបស់គណបក្សនោះប៉ុន្មានឡើយ ។ បងខ្ញុំឲ្យខ្ញុំខំអានឯកសាររបស់បក្សជាភាសាបារាំង រៀបរៀងដោយលោក ចៅ សៅ ។ ឯកសារនោះបានធ្វើការវិភាគយ៉ាងលំអិតអំពីស្ថានភាពនយោបាយ សង្គម និង សេដ្ឋកិច្ចរបស់

ប្រទេសកម្ពុជា និង អំពីកំណើត ព្រមទាំងសមិទ្ធផលរបស់គណបក្សក្នុងទសវត្សរ៍ឆ្នាំ ១៩៤០ និង ១៩៥០ ។ ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការវាយតម្លៃ និង ការវិភាគផ្នែកសង្គម និង សេដ្ឋកិច្ចរបស់លោក ថៅ សៅ ព្រមទាំងគោលនយោបាយប្រឆាំងរបប លន់ នល់ ។ ម្យ៉ាងទៀត អ្វីដែលនាំឲ្យខ្ញុំច្រួលច្រាលក្នុងចិត្តចង់ចូលរួមនោះគឺ ដោយឃើញផ្ទាល់ភ្នែកនូវឥស្សរជនល្បីៗដែលពួកយើងគ្រាន់តែធ្លាប់ឮឈ្មោះតាមវិទ្យុ ឬ សារព័ត៌មាន និង មិនដែលបានចូលជិតដូចជាលោក អ៊ិន តាំ ថៅ សៅ ឱុក ប៉ាស៊ី ជាដើមផង ។ ព្រោះពេលនោះ ខ្ញុំមិនមែនគ្រាន់តែអាចចូលរួមប្រជុំនយោបាយជាមួយពួកគាត់តែប៉ុណ្ណោះទេ តែអាចនិយាយលេងជាមួយពួកគាត់ដែលអាចចាត់ទុកជាសំណាងខ្ពស់ផងក៏បាន ។ តាមធម្មតា អស់លោកអ្នកធំៗច្រើនរស់នៅដាច់ដោយឡែកពីមហាជនដែលយើងកម្រជួបផ្ទាល់បានណាស់ ។

ខ្ញុំស្ម័គ្រចិត្តជួយធ្វើការងារគណបក្សខាងផ្នែកគណនេយ្យ ដែលជាមុខងារតូចតាចមួយ និង ជាការងារក្រៅម៉ោងធ្វើការផង ។ ខ្ញុំមិនបានដឹងថាគណបក្សបានប្រាក់ចំណូលពីណាមកទេ ។ ក៏ប៉ុន្តែ ខ្ញុំគ្រាន់តែដឹងថា កាលណាគណបក្សត្រូវការប្រាក់ អ្នកដឹកនាំមួយរូបឈ្មោះលោក ច្វាន់ គិមដាង ជាអ្នកផ្តល់ប្រាក់ឲ្យ ។ ក៏ប៉ុន្តែ ខ្ញុំមិនបានខិតខំសង្វាតធ្វើការឲ្យគណបក្សឲ្យបានជាប់លាប់ទេ ។ ខ្ញុំធ្វើឈប់ៗ ។ ក៏ប៉ុន្តែខ្ញុំតែងចូលរួមយ៉ាងទៀងទាត់នៅចុងសប្តាហ៍ ដើម្បីទៅទទួលទានអាហារពេលព្រឹកជាមួយលោក ថៅ សៅ នៅភោជនីយដ្ឋាន "ថ្មដា" ។ នៅទីនោះ លោក ថៅ សៅ មិនដែលខាតពេលវេលាទេ ។ គាត់តែងឆ្លៀតធ្វើការឃោសនាឲ្យគណបក្សរបស់គាត់ជានិច្ច ជាពិសេសនៅតាមតុកាហ្វេ ។

រៀងរាល់អាទិត្យ គណបក្សតែងធ្វើការប្រជុំ ដែលខ្ញុំចូលរួមមិនសូវខានឡើយ ។ ប៉ុន្តែ ខ្ញុំមិនមែនចូលរួម ដើម្បីសំដែងមតិអ្វីទេគឺ គ្រាន់តែស្តាប់មតិ ឬ បទអត្ថាធិប្បាយនយោបាយរបស់ថ្នាក់ដឹកនាំតែប៉ុណ្ណោះ ។ ជាធម្មតាលោក អ៊ិន

តាំ តែងបើកអង្គប្រជុំ ធ្វើការរៀបរាប់ពីសភាពការណ៍នយោបាយ និង យោធា ចំណែកឯលោក ចៅ សៅ និយាយអំពីស្ថានភាពសេដ្ឋកិច្ចនៃប្រទេសខ្មែរ ព្រមទាំងព្រឹត្តិការណ៍ពិភពលោក ។ គឺនៅក្នុងអង្គប្រជុំនោះហើយ ដែលខ្ញុំអាចសង្កេតឃើញវត្តមានបញ្ញវន្តមួយចំនួន ដែលមកចូលរួមប្រជុំ រួចក្រោយៗមកក៏បាត់ខ្លួន និង បន្តបន្ទាប់មកទៀត ឮថានាំគ្នាទៅចូលរួមជាមួយខ្មែរក្រហមក្នុង "ព្រៃម៉ាគី" ប្រឆាំងរបបលោក លន់ នល់ ជាបន្តបន្ទាប់ ។

## បោះឆ្នោតក្នុងរបបសាធារណរដ្ឋ

នៅខែ មេសា ១៩៧២ លោក លន់ នល់ បានរៀបចំប្រជាមតិនៅក្នុងទឹកដីដែលរដ្ឋការរបស់គាត់កាន់កាប់ ដើម្បីអនុម័តរដ្ឋធម្មនុញ្ញថ្មីនៃរបបសាធារណរដ្ឋ ។ នៅពេលនោះគឺ ជាការបោះឆ្នោតលើកទីមួយ និង លើកចុងក្រោយដែលខ្ញុំបានទៅចូលរួមនៅលើទឹកដីនៃប្រទេសកម្ពុជា រហូតដល់ឆ្នាំ ១៩៩៣ ទើបខ្ញុំបានបោះឆ្នោតជាថ្មីទៀត ។ កាលនោះ ខ្ញុំមិនបានបោះឆ្នោតគាំទ្ររដ្ឋធម្មនុញ្ញសារណរដ្ឋនោះទេ ។ ក្រោយមកលោក លន់ នល់ ក៏ស្នើឲ្យមានការបោះឆ្នោតជ្រើសរើសប្រធានាធីបតី តែខ្ញុំមិនបានទៅបោះឆ្នោតទៀតទេ ។ គណបក្សប្រជាធិបតេយ្យ បានជ្រើសរើសលោក អ៊ិន តាំ ឲ្យឈរឈ្មោះជាបេក្ខជនប្រធានាធិបតី ។ បេក្ខជនម្នាក់ទៀតគឺលោក កែវ អន ដែលជាព្រឹទ្ធបុរសនៃមហាវិទ្យាល័យច្បាប់ ។ គណបក្សប្រជាធិបតេយ្យ បានដឹកនាំការឃោសនាយ៉ាងគគ្រឹកគគ្រេងខ្លាំងណាស់ ។ គណបក្សនេះមានការគាំទ្រយ៉ាងច្រើន ជាពិសេសពីយុវជន ហើយនិងមានការដឹកនាំល្អ ដែលអាចឲ្យយើងម្នាក់ៗនឹកថា លោក អ៊ិន តាំ អាចនឹងទទួលជ័យជំនះក្នុងការបោះឆ្នោតប្រធានាធិបតីនោះ ។ ក៏ប៉ុន្តែនៅទីបំផុត ជ័យជំនះត្រូវបានទៅលោក លន់

នល់ ទៅវិញ ទោះបីជាលទ្ធផលនៃការរាប់សន្លឹកឆ្នោតនៅរដ្ឋធានីភ្នំពេញ បានបង្ហាញឲ្យឃើញថា លោក អ៊ិន តាំ បានសន្លឹកឆ្នោតច្រើនជាងគេ ។ នៅពេលល្ងាចនោះខ្ញុំ និង បងស៊ីនឿន នាំគ្នាទៅស្តាប់សភាពការណ៍នៅឯផ្ទះលោក អ៊ិន តាំ ។ ពួកយើងត្រៀមខ្លួនដើម្បីរៀបចំពិធីអបអរសាទរចំពោះជោគជ័យ នៃការបោះឆ្នោតទៅហើយ ក៏ប៉ុន្តែនៅពេលដែលគេទទួលលទ្ធផលនៅតាមខេត្តដែលស្ថិតនៅក្រោមការត្រួតត្រារបស់ទាហានទាំងអស់នោះ លោក លន់ នល់ បានទទួលសម្លេងគាំទ្រច្រើនជាងគេ ។ សូមបញ្ជាក់ថា លោក លន់ នល់ ត្រូវបានលោក អ៊ិន តាំ និង ក្រុមអ្នកតំណាងរាស្ត្ររបស់គាត់ លើកតំកើងជាសេនាប្រមុខនៅឆ្នាំ ១៩៧១ ។

# សម្ព័ន្ធភាព លន់ នល់ សាកល្បងរួបរួមគ្នាវិញ

លោក លន់ នល់ ត្រូវបានប្រកាសជាផ្លូវការក្នុងតំណែងជាប្រធានាធិបតីនៃសារណរដ្ឋខ្មែរនៅខែ មិថុនា ១៩៧២ ។ ក៏ប៉ុន្តែស្ថានភាពនយោបាយបានគាបសង្កត់របបសាធារណរដ្ឋកាន់តែខ្លាំងក្លាឡើងជារៀងរាល់ថ្ងៃ ។ ប្រហែលជាដោយសារមានការផ្តល់ជំនួនពីសហរដ្ឋអាមេរិកផង បានជាលោកសេនាប្រមុខ លន់ នល់ ខិតខំព្យាយាមបង្រួបបង្រួមដៃគូរបស់គាត់ ដែលធ្លាប់បានរួមគ្នាទម្លាក់សម្តេចសីហនុ និង អូសទាញក្រុមប្រឆាំងឲ្យចូលមកសហការជាមួយគាត់ ។ ក្រុមលោក លន់ នល់ បានអូសទាញលោក ឌុក រ៉ាស៊ី ដោយផ្តល់មុខតំណែងជាឯកអគ្គរដ្ឋទូតប្រចាំទីក្រុងឡុងដ៍នៃប្រទេសអង់គ្លេស ។ អ្នកដឹកនាំគណបក្សធ្វើការរិះគន់ថាលោក ឌុក រ៉ាស៊ី មានទម្លាប់ធ្វើការជាមួយអ្នកកាន់អំណាច ទោះបីជាគាត់ធ្លាប់ប្រយុទ្ធប្រឆាំងនឹងអ្នកកាន់អំណាចនោះក៏ដោយ ។ ក៏ប៉ុន្តែ ចំពោះលោក ឌុក រ៉ាស៊ី គាត់សំអាងលើទ្រឹស្តីមួយ ដែលមានយុទ្ធសាស្ត្រចូលរួមក្នុងរដ្ឋអំណាច ដើម្បីទៅវាយរំលំ

ពីខាងក្នុង[50] ។ លោក អ៊ិន តាំ នៅទីបំផុត ក៏ត្រូវអូសទាញ ហើយគាត់ក៏សុខចិត្តទទួលតំណែងជានាយករដ្ឋមន្ត្រីរបស់លោក លន់ នល់ ។ គាត់សំរេចចូលរួមបំរើលោក លន់ នល់ ដោយពុំបានពិគ្រោះជាមួយគណបក្សជាមុនឡើយ ដែលនៅទីបំផុតលោក អ៊ិន តាំ ត្រូវបានបណ្តេញចេញពីគណបក្ស ។ តាំងពីពេលនោះមកលោក ចៅ សៅ បានឡើងមកគ្រប់គ្រងគណបក្សយ៉ាងពេញទំហឹង ។ នៅទសវត្សរ៍ឆ្នាំ ១៩៤០ គណបក្សនេះក៏ធ្លាប់បានបណ្តេញលោក ស៊ឹម វ៉ា ដែលជាអ្នកដឹកនាំដ៏ល្បីមួយរូបឲ្យចេញពីតំណែងប្រធានគណបក្សដែរ ។

## ក្រុមប្រជាធិបតេយ្យចង់ធ្វើជាស្ពានឈានទៅបញ្ចប់សង្គ្រាម

ប៉ុន្មានខែមុនខ្ញុំចេញដំណើរទៅប្រទេសបារាំង ខ្ញុំ និង បងស៊ីុនឿន ព្រមទាំងមិត្តភក្តិខ្លះទៀត តែងនាំគ្នាជិះឡាន 2CW ជាមួយលោក ចៅ សៅ ធ្វើដំណើរជុំវិញក្រុងភ្នំពេញ ។ ពួកយើងតែងផ្លាស់ប្តូរគំនិតគ្នាអំពីវិធីណាខ្លះ ដែលយើងអាចប្រើក្នុងការគ្រប់គ្រងប្រទេស ប្រសិនបើគណបក្សប្រជាធិបតេយ្យ ត្រូវឡើងកាន់អំណាច ។ នៅពេលនោះ យើងលើកបញ្ហាអំពើពុករលួយដែលកំពុងស៊ីរូងសង្គមខ្មែរយ៉ាងជ្រៅ ហើយដែលកំពុងគំរាមកំហែងអនាគតរបស់យើងមកពិភាក្សាគ្នា ។ ពួកយើងនឹកឃើញថា បញ្ហានោះមិនងាយដោះស្រាយបានឡើយ ក៏ប៉ុន្តែក្នុងចំណោមយើងនោះ ក៏មានម្នាក់និយាយបែបកំប្លែងលេងថា អ្នកដែលប្រព្រឹត្តអំពើពុករលួយគួរតែត្រូវសំលាប់ចោល។ នៅក្នុងចិត្តពួកយើង គ្មាននរណានឹកដល់ការកាប់សំលាប់នរណាម្នាក់ងាយៗនោះទេ ។ ចំពោះពួកយើងៗគ្រាន់តែនិយាយលេងបែបកំប្លុក

[50] នេះជាមតិដែលមេដឹកនាំគណបក្សប្រជាធិបតេយ្យ ជាពិសេស លោក ចៅ សៅ ធ្លាប់បកស្រាយប្រាប់ពួកយើងក្មេងៗ នាសម័យនោះ ។

កំប្លែងតែប៉ុណ្ណោះ ផ្ទុយពីក្រុមខ្មែរក្រហម ដែលបានកាប់សំលាប់ប្រជាពលរដ្ឋ និង មន្ត្រីរដ្ឋការរបស់របបលោក លន់ នល់ ស្ទើរតែទាំងអស់យ៉ាងឃោរឃៅបំផុត ។

ពួកអ្នកប្រជាធិបតេយ្យក៏បានសាកល្បងធ្វើជាស្ពាន ដើម្បីឲ្យមានការចរចាគ្នារវាងសាធារណរដ្ឋខ្មែររបស់លោក លន់ នល់ ជាមួយនឹងភាគីម្ខាងទៀតគឺ រណសិរ្សខ្មែរក្រហមដែលមានព្រះនាមសម្ដេច សីហនុ ជាអ្នកដឹកនាំ ។ នៅពេលនោះ ប្រជាពលរដ្ឋខ្មែរភាគច្រើននៅភ្នំពេញ និង នៅទីដ៏ទៃទៀត ប្រហែលរួមទាំង សម្ដេច សីហនុ ផង មានជំនឿថាមេខ្មែរក្រហមធំជាងគេគឺ លោក ខៀវ សំផន ។ ជាដំបូង ខ្ញុំក៏មានជំនឿបែបនេះដែរ ។ ហើយខ្ញុំក៏មានបំណងចង់ទៅចូលរួមរណសិរ្សរបស់សម្ដេច សីហនុ នៅឯទីក្រុងប៉េកាំងដែរ ។ នៅពេលដែលខ្ញុំជំរាបគាត់ពីផែនការនេះ និង គោលបំណងរបស់ខ្ញុំក្នុងការចាកចេញពីប្រទេសកម្ពុជាទៅប្រទេសបារាំងនោះ លោក ថៅ សៅ បានទូន្មានកុំឲ្យសំរេចចិត្តយ៉ាងរាក់កំភែលបែបនេះ ព្រោះគាត់ដឹងច្បាស់ថាមិនមែនសម្ដេច សីហនុ ឬ លោក ខៀវ សំផន ទេ ដែលជាអ្នកដឹកនាំអង្គការខ្មែរក្រហមនោះ ។ ក៏ប៉ុន្តែលោក ថៅ សៅ ក៏មិនបានប្រាប់ខ្ញុំអំពីលោក សាឡុត ស ឬ ប៉ុល ពត ដែរទេ គាត់គ្រាន់តែនិយាយអំពីប្រវត្តិនៃចលនាកុម្មុយនីស្តឥណ្ឌូចិន ។ គាត់និយាយថា អ្នកដឹកនាំពិតប្រាកដនៃចលនាកុម្មុយនីស្តស្ថិតនៅក្នុងភាពងងឹតជានិច្ច ។ ពួកគេមិនដែលបើកចំហរឲ្យគេស្គាល់ជាសាធារណៈនោះទេ ។ លុះត្រាដល់ពេលគេឡើងកាន់អំណាច ទើបគេបញ្ចេញមុខ ។ លោក ថៅ សៅ ក៏បានពន្យល់អំពីប្រវត្តិសាស្ត្រផ្សេងៗ ដែលមេកុម្មុយនីស្តសម្លាប់គ្នាម្ដងមួយៗ ។ លោក ថៅ សៅ បានផ្ដែផ្ដាំខ្ញុំកុំឲ្យធ្វើអ្វីផ្ដេសផ្ដាសឲ្យសោះគឺ ឲ្យខ្ញុំនៅអព្យាក្រឹត្យ ក៏ប៉ុន្តែឲ្យខ្ញុំខិតខំថែរក្សាទំនាក់ទំនងល្អជាមួយសហគមន៍ខ្មែរនៅឯបរទេសនោះ ឲ្យបានច្រើនជាទីបំផុត ។

បងស៊ីនឿន ក៏ខិតខំខ្លាំងណាស់ដែរ ដើម្បីទំនាក់ទំនងជាមួយឪពុកមាខ្ញុំ

ដែលជាគណៈស្រុកនៃចលនាខ្មែរក្រហម នៅស្រុកពារាំង ដែលជាស្រុកកំណើតរបស់ខ្ញុំ ។ ខ្ញុំមិនបានដឹងថា បងស៊ីនឿន បានទទួលអាណត្តិពីគណបក្សឲ្យទៅធ្វើការទាក់ទងជាមួយឪពុកមាខ្ញុំនោះទេ ។ ក៏ប៉ុន្តែ ខ្ញុំហាក់ដូចជាយល់ថានោះគឺ ជានយោបាយរបស់គណបក្ស ដើម្បីបញ្ចប់សង្គ្រាមតាមរយៈការចរចាគ្នា ។ បងប្រុសខ្ញុំ ផ្ញើសំបុត្រយ៉ាងខ្លីពីរដងទៅឪពុកមាខ្ញុំ តែគាត់មិនដែលបានទទួលចម្លើយម្តងណាឡើយ ។ ក៏ប៉ុន្តែ ចំពោះសំបុត្រទីបី ឪពុកមាខ្ញុំឆ្លើយយ៉ាងខ្លីតែពីរម៉ាត់ថា "កុំធ្វើអ្វី និង នៅឲ្យស្ងៀម" ។ នៅឆ្នាំ ១៩៧៧ ឪពុកមាខ្ញុំ ក៏ត្រូវខ្មែរក្រហមចាប់ខ្លួន និង យកទៅសម្លាប់ចោលដូចកម្មាភិបាលខ្មែរក្រហមមួយចំនួនធំទៀតដែរ ។

សូមរំលឹកថាលោក សឺន សាន ដែលឡើងកាន់តំណែងជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុនៅក្នុងរដ្ឋាភិបាល រៀបចំឡើងដោយគណបក្សប្រជាធិបតេយ្យ នៅឆ្នាំ ១៩៤៦ និង ដែលក្រោយមកក៏បានក្លាយជាមេដឹកនាំចលនាតស៊ូនាសម័យប្រឆាំងកងទ័ពវៀតណាមនៅទសវត្សរ៍ឆ្នាំ ១៩៨០ នោះ ក៏ធ្លាប់បានដើរតួនាទីដើម្បីជំរុញឲ្យមានការចរចាផ្សះផ្សារគ្នារវាងលោក លន់ នល់ និង សម្តេច សីហនុ ដែរ ។ ដោយធ្លាប់មានស្នាដៃល្អ និង មានស្វាមីភក្តិជាច្រើនឆ្នាំចំពោះសម្តេច សីហនុ និង ដោយសារមានទំនាក់ទំនងល្អជាមួយលោក លន់ នល់ ផងនោះ លោក សឺន សាន ប្រហែលនឹកថា នឹងអាចធ្វើជាស្ពានឲ្យមានការចរចាគ្នាបាន ។ នៅពេលដំបូងនៃជម្លោះគឺ នៅពេលដែលលោក លន់ នល់ កំពុងតែមានឥទ្ធិពលខ្លាំង ហើយនៅពេលដែលសម្តេច សីហនុ កំពុងនៅអន់ខ្សោយនៅឡើយនោះ លោក លន់ នល់ ប្រកែកមិនព្រមចរចា ។ ក្រោយមកនៅពេលសភាពការណ៍រឹតតែដុនដាបទៅ លោក លន់ នល់ ចុះខ្សោយ ហើយក៏សុខចិត្តចរចា ក៏ប៉ុន្តែ សម្តេច សីហនុ នៅឯទីក្រុងប៉េកាំង ប្រកែកពុំព្រមចរចាម្តងវិញ ។ ខ្មែរយើងភាគច្រើននឹកថាប្រហែលជាស្រុកយើងត្រូវទំនាយថាត្រូវតែកើតសង្គ្រាមរងទុក្ខវេទនាបែបនេះ ព្រោះថាប្រសិនបើភាគីទាំងសង

ខាងសុខចិត្តយល់ព្រមចរចារកវិធីដោះស្រាយជម្លោះតាមសន្តិវិធីវិញ ប្រហែលយើងមិនរងកម្មខ្លោចផ្សាយ៉ាងនេះទេ ។ ក៏ប៉ុន្តែ ចំពោះខ្ញុំៗយល់ឃើញថានេះជាអត្តចរិតអាក្រក់មួយរបស់ខ្មែរ ។ នៅពេលណាគេនឹកថាគេខ្លាំង គេមិនព្រមសម្រុះសម្រួលគ្នាជាមួយគូបដិបក្ខទេ ។

## ការចុះទន់ខ្សោយនៃរបប លន់ នល់

ដោគជ័យរបស់ពួកខ្មែរក្រហមដែលបានផ្តួលរំលំរបប លន់ នល់ ក្នុងខែមេសា ១៩៧៥ ជាព្រឹត្តិការណ៍ដ៏ខ្លោចផ្សាមួយ បានរុញច្រានប្រជារាស្ត្រ និង ប្រជាជាតិខ្មែរឲ្យធ្លាក់ចូលក្នុងមហាសោកនាដកម្មមួយអស់រយៈពេល បីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ មុននឹងត្រូវទទួលការវាយរំលំ ពីកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដោយមានជំនួយពីកងទ័ពវៀតណាម ។ មូលហេតុដែលនាំឲ្យខ្មែរក្រហមឈ្នះសង្គ្រាមនោះមានច្រើនយ៉ាង ។ ម្យ៉ាងគឺរបប លន់ នល់ ជារបបទន់ខ្សោយដែលគ្មានលទ្ធភាពអាចរស់រានមានអាយុបានដោយខ្លួនឯង ប្រសិនបើគ្មានជំនួយពីក្រៅប្រទេស ។ ការដកខ្លួនថយរបស់សហរដ្ឋអាមេរិកពីសង្គ្រាមនៅវៀតណាម និង នៅតំបន់នាសម័យនោះ ក៏ជាកត្តាជួយជំរុញឲ្យរបបសាធារណរដ្ឋខ្មែររបស់លោក លន់ នល់ ឆាប់រលំរលាយថែមទៀតដែរ ។ ម្យ៉ាងទៀតនៅក្នុងសង្គ្រាមត្រជាក់ពួកខ្មែរក្រហមបានទទួលការគាំទ្រសាមគ្គីសង្គមនិយមអន្តរជាតិ ដែលអាចឲ្យពួកគេមានលទ្ធភាពចាត់តាំងអង្គការ និង កាន់កាប់ប្រទេសទាំងមូលបាន ។ លើសពីនេះទៅទៀត ពួកខ្មែរក្រហមបានទទួលការគាំទ្រពីសម្តេច សីហនុ ដែលមានតំលៃថ្លៃថ្លាចំពោះបដិវត្តន៍ខ្មែរក្រហម ។ សាធារណរដ្ឋខ្មែរ បានធ្លាក់ខ្លួននៅក្នុងស្ថានភាពមួយដ៏ទន់ខ្សោយជាទីបំផុតគឺ ភាពទន់ខ្សោយខាងផ្នែកនយោបាយ និង បន្ទាប់មកទន់ខ្សោយខាងផ្នែកយោធា ។ បន្ទាប់ពីពួកគេនាំគ្នាទម្លាក់សម្តេច សីហនុ ចេញភ្លាម

គឺនៅពេលប្រទេសកំពុងធ្លាក់ចូលក្នុងភ្លើងសង្គ្រាមដ៏សន្ធោសន្ធៅនោះ ដែលទាមទារឲ្យមានការប្រមែប្រមូលផ្តុំកំលាំងជាតិទាំងមូល របបសាធារណរដ្ឋបែរជាជាប់ផុងក្នុងការបាក់បែកគ្នាជាក្រុមជាបក្សជាពួក ប្រឆាំងតែគ្នាឯងទៅវិញ ។ ការប្រកាន់បក្សពួកមិនបានជួយពង្រឹងឯកភាពជាតិឡើយ ។ នៅពេលនោះ ពួកគេត្រូវប្រឈមមុខនឹងការបែកបាក់ផ្ទៃក្នុងផង ប្រឈមមុខនឹងពួករាជានិយមផង ពួកកុម្មុយនីស្តខ្មែរក្រហមផង បូកផ្សំជាមួយនិងការបាត់បង់នូវការគាំទ្រពីប្រជាពលរដ្ឋខ្មែរភាគច្រើនផង ។ អំពើអនាធិបតេយ្យ ក៏លេចចេញឡើង ព្រមៗគ្នាជាមួយអំពីពុករលួយដែលចេះតែរីកធំធាត់ឡើង និង ស៊ីរូងសង្គមខ្មែរយ៉ាងខ្លាំង ។ នៅទីបំផុត ស្ថានភាពនោះក៏នាំទៅរកភាពរលំរលាយនៃរបបសាធារណរដ្ឋទាំងមូលតែម្តង ។

ខាងផ្នែកយោធាកងទ័ពសាធារណរដ្ឋ ត្រូវបានប្រមូលផ្តុំជាកងឯកភាពធំៗ មានទីតាំងនៅក្នុងបន្ទាយដើម្បីការពារទីក្រុងធំៗ និង រដ្ឋធានីភ្នំពេញ ។ កងឯកភាពទាំងនោះ ប្រើយុទ្ធវិធីធ្វើចលនាពេលថ្ងៃ និង សំរាកពេលយប់ ។ ឯទ័ពខ្មែរក្រហមធ្វើផ្ទុយពីនេះ ។ ពួកគេនាំគ្នាកាន់កាប់ភូមិ និង រៀបចំការប្រយុទ្ធនៅពេលយប់ ។ ពួកគេបាញ់កាំភ្លើងបំផ្លោងគ្រាប់ចូលបន្ទាយទាហាន កាត់ផ្តាច់ខ្សែផ្គត់ផ្គង់ស្បៀង ភារ ។ គេធ្វើការរំដោះភូមិ ដើម្បីទៅឡោមព័ទ្ធទីក្រុង នៅពេលដែលមេទ័ពសាធារណរដ្ឋមួយភាគធំ គិតតែប្រព្រឹត្តអំពើពុករលួយប្រមែប្រមូលទ្រព្យសម្បត្តិ ពុំបានចេញទៅចូលរួមក្នុងសង្គ្រាមដោយផ្ទាល់ និង ចេះតែបញ្ជាពីចម្ងាយតែប៉ុណ្ណោះ ។ ទឹកចិត្តកូនទាហានក៏ធ្លាក់ចុះ ។ ពួកកូនទាហាននោះ ក៏នាំប្រពន្ធកូនទៅរស់នៅជាមួយនៅក្នុងបន្ទាយ ឬ ក៏នៅទីលានប្រយុទ្ធខាងមុខ ។ ចំពោះពួកខ្មែរក្រហម គេគិតគូរតែរឿងពង្រឹងកំលាំង ដើម្បីវាយកំទេចរបប លន់ នល់ និង ក្តាប់អំណាចយ៉ាងណែននៅក្នុងតំបន់រំដោះតាមគ្រប់រូបភាព ។

# ខ្មែរក្រហមប្រើល្បិចដើម្បីឈ្នះសង្គ្រាម

នៅក្នុងតំបន់ដែលឥទ្ធិពលពួកគេនៅមិនទាន់រឹងមាំ ពួកខ្មែរក្រហមប្រើនយោបាយលួងលោម ដោយយកព្រះនាមសម្តេច សីហនុ ទៅប្រើ ។ គេថាពួកគេជាកងទ័ពរបស់សម្តេច សីហនុ ។ គេមកបំរើប្រជាពលរដ្ឋ មកការពារប្រជាពលរដ្ឋ ។ មានពេលខ្លះពួកគេជួយធ្វើស្រែចំការអ្នកស្រុក ឬ ជួយឃ្វាលគោ ជួយបោសសំអាតផ្ទះសម្បែងរបស់អ្នកស្រុក ជួយថែរក្សាអ្នកជម្ងឺ ។ល។ មានករណីខ្លះ ប្រសិនបើកូនទាហានខ្មែរក្រហមបេះបោចផលដំណាំអ្នកស្រុកដោយមិនបានសុំជាមុន ពួកគេមិនភ្លេចចងបន្សល់ទុកនូវសំបុត្រអភ័យទោស ឬ ពាក្យពេចន៍ផ្អែមល្ហែម ឬ ជួនកាលមានទុកប្រាក់កាសឲ្យផង ។ ដោយសារតែល្បែងសង្គ្រាមចិត្តសាស្ត្រយ៉ាងនេះហើយ ទើបពួកគេឈ្នះសង្គ្រាម ។ នៅក្នុងភូមិស្រុកដែលពួកគេក្តាប់អំណាចបានណែនហើយនោះ ពួកខ្មែរក្រហមក៏ប្រើកំលាំង ឬ អំពើកាចសាហាវយង់ឃ្នងដើម្បីពង្រឹងឥទ្ធិពលរបស់គេ លាយឡំជាមួយនឹងសង្គ្រាមចិត្តសាស្ត្រ តាមវិធីធ្វើការឃោសនារបស់ពួកកុម្មុយនីស្ត ។ បន្ថែមលើនេះ ពួកគេធ្វើការឃោសនាដែលសង្កត់ធ្ងន់លើសង្គ្រាមរំដោះជាតិឲ្យរួចចេញពី "ចក្រព័ត្រអាមេរិក និង ពួកខ្ញុំកញ្ជះវា" គឺជាសង្គ្រាមរំដោះជាតិមួយ ដែលដឹកនាំដោយអគ្គមគ្គុទេសក៍ ដែលគេជឿថាស្របច្បាប់គឺ សម្តេច សីហនុ ។ តាមប្រពៃណីរាជានិយម នៅប្រទេសកម្ពុជាយើង ប្រជារាស្ត្រមួយចំនួនធំនៅតែទទួលស្គាល់ព្រះអង្គថា ជាអ្នកមានបុណ្យ ជាស្តេចលើពួកគេ ។ ឯចំណែកសម្តេច សីហនុ ព្រះអង្គឯងវិញ ក៏ទ្រង់យល់ដឹងនូវជំរៅទឹកចិត្តរបស់ប្រជារាស្ត្ររបស់ព្រះអង្គដែរ ។ ព្រះអង្គតែងមានបន្ទូលថា "កូនចៅរាស្ត្រតូចតាច" ហើយព្រះអង្គក៏ចេះទាក់ទាញការគាំទ្រពីប្រជារាស្ត្រតូចតាចនោះ តាមរយៈព្រះរាជសារដ៏ញឹកញាប់ ដែលព្រះអង្គផ្ញើពីទីក្រុងប៉េកាំងមក ។ សម្តេច សីហនុ

ក៏ទ្រង់ជ្រាបដែរថាពួកខ្មែរក្រហមគ្រាន់តែយកព្រះអង្គទៅប្រើជាឈ្នាន់ ដើម្បីឲ្យពួកគេបានឈានឡើងកាន់អំណាចតែប៉ុណ្ណោះ ។ ព្រះអង្គធ្លាប់មានព្រះរាជបន្ទូលប្រាប់អ្នកកាសែតបរទេសថាពួកខ្មែរក្រហម នឹងបោះបង់ព្រះអង្គចោល ដូចគេខ្ជាក់គ្រាប់ផ្លែស៊ីរីចេញយ៉ាងដូច្នោះដែរ ។ បើយើងមើលទៅ ប្រហែលជាសម្តេចមានការគុំគួនយ៉ាងខ្លាំងចំពោះក្រុមលោក លន់ នល់ ដែលទម្លាក់ព្រះអង្គចេញពីតំណែង ឬ ទំនងជាព្រះអង្គពុំមានផ្លូវឯណាទៀត ក្រៅពីសហការជាមួយពួកខ្មែរក្រហម ដើម្បីទ្រង់ដណ្តើមយកអំណាចមកវិញឲ្យបាននោះ ទើបសម្តេចសុខចិត្តរួបរួមជាមួយពួកនេះ ។ នៅទីបំផុត ពួកខ្មែរក្រហម ក៏បោះបង់ព្រះអង្គចោលមែន ។ នៅពេលដែលពួកគេទទួលជោគជ័យផ្តួលរំលំរបប លន់ នល់ ហើយនោះ ពួកខ្មែរក្រហមពុំបានប្រញាប់យាងសម្តេចឲ្យទ្រង់ចូលនិវត្តមកមាតុភូមិវិញភ្លាមទេ ។ ពួកគេរង់ចាំ រហូតដល់ខែ កញ្ញា ១៩៧៥ ទើបយាងសម្តេចមកទីក្រុងភ្នំពេញ ក្នុងរយៈពេលដ៏ខ្លី មុននឹងបញ្ជូនព្រះអង្គឲ្យទៅថ្លែងសុន្ទរកថានៅអង្គការសហប្រជាជាតិ ក្នុងនាមពួកខ្មែរក្រហម នៅទីក្រុងញូវយ៉ក ។ សម្តេចយាងត្រឡប់មកប្រទេសកម្ពុជាវិញ នៅខែ ធ្នូ ១៩៧៥ ក្នុងឋានៈព្រះអង្គជាប្រមុខរដ្ឋ ដែលគ្មានអំណាចអ្វីទាំងអស់ ។ សម្តេចសីហនុ បានទ្រង់លាឈប់ពីតំណែងជាព្រះប្រមុខរដ្ឋខ្មែរក្រហម ឬ កម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី ២ មេសា ១៩៧៦ ។

ដោយសារអំពើឃោរឃៅយ៉ាងខ្លាំងក្លា ពួកខ្មែរក្រហមបានបង្កើតនូវរដ្ឋអំណាចមួយដែលបង្ហូរឈាមប្រជារាស្ត្រឯងដ៏ធំអស្ចារ្យនៅក្នុងពិភពលោក ។ អំពើប្រល័យពូជសាសន៍ ឬ បើនិយាយឲ្យចំអំពើស្វ័យប្រល័យពូជសាសន៍បានទទួលការផ្តន្ទាទោសយ៉ាងធំធេង និង ការខ្ចើមរអើមពីសំណាក់អន្តរជាតិ ។ ក្រៅពីវិធីពិសេសរបស់ពួកគេក្នុងការកាប់សម្លាប់ គេអាចសង្កេតឃើញចំណុចមួយចំនួនធំដែលឆ្លុះបញ្ចាំងនូវលក្ខណៈនៃរបបផ្តាច់ការនិយមគឺៈ ការអប់រំឲ្យស្អប់ខ្ពើមគ្នា ការ

កំទេចចោលនូវប្រព័ន្ធក្រុមគ្រួសារ ការកំទេចចោលនូវប្រពៃណីសង្គម និង អារ្យធម៌ ទំនៀមទម្លាប់ពីបុរាណកាល ការប្រឌិតខ្មាំងសត្រូវ ការបង្កើតមនុស្សថ្មីនៅក្នុងសង្គមថ្មី អំណាចដ៏ធំធេងរបស់បក្ស និង ថ្នាក់ដឹកនាំបក្ស ។ល។ ក្នុងរយៈពេលនៃការគ្រប់គ្រងប្រទេសរបស់ពួកគេ ពួកខ្មែរក្រហមមិនត្រឹមតែកាប់សម្លាប់ផ្តាច់ជីវិតជនជាតិខ្មែររាប់លាននាក់ប៉ុណ្ណោះទេ ពួកគេក៏បានកាត់ផ្តាច់នូវទងព្រលឹងរបស់ជាតិខ្មែរដែរ ។ មានសៀវភៅ និង អត្ថបទជាច្រើនដែលបានរៀបរាប់រួចមកហើយ និងយ៉ាងលំអិតនូវវិធី ឬ យុទ្ធសាស្ត្របំផ្លិចបំផ្លាញវប្បធម៌ ប្រពៃណីជាតិ ទំនៀមទម្លាប់ជាតិ ដោយមិនទាន់និយាយអំពីការលុបបំបាត់នូវសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្សផង ។ ខ្ញុំទំនងជាមនុស្សម្នាក់ ក្នុងចំណោមមនុស្សមួយចំនួនតូចដែលមានភ័ព្វសំណាង បានគេចរួចពីអំពើព្រៃផ្សៃកាប់សម្លាប់នៃពួកខ្មែរក្រហម ។ ក៏ប៉ុន្តែខ្ញុំក៏ដូចជាគ្រួសារខ្មែរស្ទើរតែទាំងអស់ ដែលបានបាត់បង់មនុស្សជាទីស្រឡាញ់ ដោយសារអំពើសាហាវយង់ឃ្នងរស់ពួកព្រៃផ្សៃនេះ ។ ឪពុកខ្ញុំស្លាប់នៅក្នុងឆ្នាំ ១៩៧៥ ដោយសារការអត់ឃ្លាន ។ បងឈឿន បងស៊ីនឿន និង ប្អូនប្រុសពីរនាក់ទៀតគឺៈ ណារីន និង វុធធៀន ត្រូវគេបញ្ជូនទៅជំរុំ "អប់រំ" នៅឆ្នាំ ១៩៧៧ ហើយក៏បាត់ដំណឹងសូន្យឈឹងរហូតមក ។

## មហាវិនាសកម្មត្រូវចងចាំជាមេរៀនប្រវត្តិសាស្ត្រ

វគ្គនេះនៃប្រវត្តិសាស្ត្រទំនើបរបស់កម្ពុជា ត្រូវបានកត់សំគាល់ដោយការរងទុក្ខវេទនា ដោយសង្គ្រាមឥតឈប់ឈរ និង ដោយការបំផ្លិចបផ្លាញដ៏មហិមា ។ ក៏ប៉ុន្តែដើម្បីខ្មែរជំនាន់ក្រោយ ខ្មែរគ្រប់រូបគប្បីដកស្រង់ យកមេរៀនពីព្រឹត្តិការណ៍ដ៏អភ័ព្វទាំងនោះ ។ មេរៀនទីមួយ ដែលខ្មែរយើងត្រូវរៀនសូត្រគឺ ត្រូវចេះសំរុះសំរួលគ្នា រស់នៅជាមួយគ្នា និង គោរពគ្នាទៅវិញទៅមក ទោះបីជាយើងប្រឆាំង ឬ

ប្រណាំងប្រជែងគ្នាយ៉ាងណាក៏ដោយ ។ កាលពីអតីតកាល អ្នកដឹកនាំខ្មែរយើងច្រើនទទួលមត៌កនូវវប្បធម៌នៃអំណាចប្រមូលផ្តុំ ឬ អំណាចផ្តាច់ការ ។ អ្នកដឹកនាំទាំងនោះ មិនបានរិះរកនូវវិធីសាស្ត្រនៃការចែករំលែក ឬ នូវតុល្យភាពនៃអំណាចនោះឡើយ ។ រាល់ៗដង នៅពេលដែលយើងមានជម្លោះផ្ទៃក្នុង យើងកម្រនឹងអាចសំរុះសំរួល ឬ ផ្សះផ្សាគ្នាណាស់ ។ អ្នកឈ្នះមិនដែលទុកឲ្យអ្នកចាញ់អាចរួមរស់នៅជាមួយបានឡើយ ឯអ្នកចាញ់ក៏គ្មានជំរើសអ្វី ក្រៅពីស្វែងរករស់ដោយខ្លួនឯងដែរ ។ ពួកគេរង់ចាំពេលវេលាមកដល់ ដើម្បីធ្វើការសងសឹកវិញ ។

បើនិយាយតាមធម៌របស់ព្រះពុទ្ធ គ្មានអ្វីដែលមានភាពអមតៈ មិនប្រែប្រួលនោះឡើយ ។ នោះរាប់ទាំងជ័យជំនះ និង បរាជ័យផង ។ ដូច្នេះរវាងខ្មែរ និង ខ្មែរ ទាំងអ្នកឈ្នះ និង អ្នកចាញ់ត្រូវតែចេះត្រៀមខ្លួនរិះរករូបមន្ត ដើម្បីធ្វើការផ្សះផ្សាគ្នា ។ ក្នុងកាលកន្លងមក ជាទម្លាប់ទូទៅ នៅពេលដែលខ្លួនបានសេចក្តីសុខ ឬ មានសុវត្ថិភាពហើយ អ្នកចាញ់ក៏មិនដែលទទួលស្គាល់ពីបរាជ័យរបស់ខ្លួនដែរ ហើយក៏តែងតែទៅសុំឲ្យបរទេសចូលរួមនៅក្នុងជម្លោះ ជាពិសេស អ្នកនៅជិតខាងយើងអាស្រ័យទៅតាមកាលៈទេសៈ ដើម្បីឲ្យបរទេសអ្នកជិតខាងទាំងនោះ ជួយពួកគេដែលចាញ់ទៅហើយនោះ ឲ្យត្រឡប់មកកាន់អំណាចវិញ ។ រាល់ៗដង អ្នកជិតខាងរបស់យើងទាំងនោះ ក៏មានចិត្តសប្បុរសជួយផ្តល់មធ្យោបាយឲ្យខ្មែរកាប់សម្លាប់គ្នាតទៅទៀត ។ ជួនកាល អ្នកជិតខាងទាំងនោះក៏បានទទួលផលចំណេញអំពីការអន់ថយរបស់ខ្មែរដែរ ។

មេរៀនដ៏សំខាន់មួយទៀតសំរាប់ខ្មែរគឺ ត្រូវហ៊ានទទួលខុសត្រូវចំពោះសកម្មភាព ឬ អំពើដែលខ្លួនបានធ្វើ ។ នៅក្នុងព្រឹត្តិការណ៍នៃការដួលរំលំរបស់កម្ពុជានៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ ឬ ការដួលរំលំរបស់របប លន់ នល់ ឬ ការឡើងកាន់អំណាចនៃរបបខ្មែរក្រហមនៅឆ្នាំ ១៩៧៥ ខ្ញុំពុំទាន់ឃើញមានថ្នាក់ដឹកនាំខ្មែរ

សម័យនោះណាម្នាក់ទទួលស្គាល់ការទទួលខុសត្រូវចំពោះសកម្មភាព ឬ អំពើដែលខ្លួនបានធ្វើឡើយ ក្រៅពីទំលាក់កំហុសទៅអ្នកឯទៀត ។ ជាការពិតណាស់ ខ្មែរយើងភាគច្រើនរួមទាំងសម្តេច សីហនុ ផងតែងនាំគ្នាថ្កោលទោសលោក លន់ នល់ ចំពោះព្រឹត្តិការណ៍ខែ មីនា ១៩៧០ ដែលនាំប្រទេសកម្ពុជា យើងធ្លាក់ចូលក្នុងភ្លើងសង្គ្រាម ។ ចំណែកឯលោក លន់ នល់ ត្រូវបក្សពួកគាត់ស្តីបន្ទោសថាជាអ្នកទទួលខុសត្រូវធំជាងគេ ក្នុងការដួលរលំនៃរបបសាធារណរដ្ឋខ្មែរ ។ នាយទាហានថ្នាក់ឧត្តមសេនីយជាច្រើននាក់ ដែលខ្ញុំបានជួបនាទសវត្សរ៍ឆ្នាំ ១៩៨០ មិនដែលទទួលស្គាល់អំពីការខ្វះខាតនូវសមត្ថភាព ឬ ភាពបរាជ័យរបស់ពួកគាត់ឡើយ ក្រៅពីលើកទោសដាក់កំហុសទៅលើលោក លន់ នល់ តែម្នាក់ឯងប៉ុណ្ណោះ ។ រីឯមេដឹកនាំខ្មែរក្រហមវិញ មិនដែលទទួលស្គាល់ការទទួលខុសត្រូវរបស់ខ្លួនទេ ចំពោះអំពើកាប់សម្លាប់ប្រជាពលរដ្ឋខ្មែរគ្នាឯងនោះ ។ ពួកគេច្រើនតែទំលាក់កំហុសទៅលើភ្នាក់ងារសម្ងាត់វៀតណាម ដែលគេចោទថាមកធ្វើវិទ្ធង្សនា កាប់សម្លាប់ប្រជាពលរដ្ឋខ្មែរទៅវិញ ។

ចំណុចសំខាន់ គេមិនត្រូវភ្លេចថារបបគ្រប់គ្រងរដ្ឋដែលអាចគង់វង្ស រឹងប៉ឹង និង រុងរឿងឡើងបាន អាស្រ័យលើការចូលរួមគាំទ្រពីប្រជាពលរដ្ឋ ។ របប ប៉ុល ពត មិនបានគិតគូរដល់ប្រជាពលរដ្ឋនោះទេ ទើបត្រូវដួលរលំយ៉ាងឆាប់រហ័សបែបនេះ ។ ពួកគេគិតថាឲ្យតែមានអំណាច អ្វីៗគេអាចធ្វើបានទាំងអស់ រួមទាំងការកាប់សម្លាប់មនុស្ស និង រំលោភសិទ្ធិមនុស្សផង ។ មេដឹកនាំខ្មែរក្រហម តែងតែឃោសនាមិនដាច់ពីមាត់ថា ពួកគេធ្វើបដិវត្តន៍ដើម្បីរំដោះជាតិឲ្យជាតិមានសេរីភាព ឲ្យប្រជាជនមានសុភមង្គល នៅពេលដែលគេគិតតែពីកាប់សម្លាប់ប្រជាជនទាំងនោះ ។ ពួកគេយកពាក្យស្នេហាជាតិធ្វើជារនាំង ដើម្បីកាប់សម្លាប់ជាតិឯងទៅវិញ ។ មេរៀនចុងក្រោយដែលយើងត្រូវរៀនសូត្រនោះគឺ គប្បីផ្តល់សិទ្ធិ សេរីភាព

និង ឯករាជភាពដល់ពួកប្រវត្តិវិទូក្នុងការសរសេរកត់ត្រាប្រវត្តិសាស្ត្រ ។ កាលពីសម័យមុន អ្នកដឹកនាំខ្មែរមួយចំនួន តែងព្យាយាមកែប្រែប្រវត្តិសាស្ត្រ ដើម្បីលើកកំពស់តួបុគ្គលរបស់ខ្លួន សកម្មភាពរបស់ខ្លួន ឬ របបរបស់ខ្លួនរហូតដល់ហ៊ានកែបំភ្លៃការពិត ឬ បំផ្លាញចោលនូវដានរបស់អ្នកមុនៗ នេះមិនទាន់គិតដល់គូប្រឆាំង ឬ គូសត្រូវដែលគេត្រូវតែបំភ្លេចចោលកុំឲ្យឃើញស្រមោលតទៅទៀតផង។ តើគេអាចសិក្សាពីអតីតកាល ដើម្បីលើកយកជាបទពិសោធន៍បានឬទេ? ប្រសិនបើប្រវត្តិសាស្ត្រត្រូវគេបំភ្លៃរួចទៅហើយនោះ ។

ដោយលើកយកមេរៀនពីអតីតកាលនេះ ខ្ញុំយល់ឃើញថា យើងគប្បីសម្លឹងទៅអនាគតក្នុងន័យប្រាកដនិយម ។ ខ្ញុំសរសេរវគ្គនេះដើម្បីគូសសំគាល់នូវភាពធ្ងន់ធ្ងរនៃមហាវិនាសកម្ម ដោយខ្ញុំនៅរក្សាកូនចិត្តនឹកសង្ឃឹមថាតម្លៃខូចខាតដែលខ្មែរយើងបានបង់ហួសទៅហើយនោះ នៅក្នុងព្រឹត្តិការណ៍ដ៏សង្វេគខ្លោចផ្សាកន្លងមក អាចនឹងជួយកែឆ្នៃការបាត់បង់ ឬ មហន្តរាយទាំងនោះ ឲ្យក្លាយទៅជាទុន ដើម្បីលើកកំពស់សីលធម៌នៃការដឹកនាំ និង កសាងប្រព័ន្ធសតិសម្បជញ្ញៈមួយ បង្កើតជាចរិយាធម៌ ឬ គុណធម៌នយោបាយ ដែលត្រូវតែស្ថិតនៅជាប់ជាប្រចាំ ជួយការពារកុំឲ្យយើងភ្លេចខ្លួន ដោយយើងមិនធ្វើការប្រុងប្រយ័ត្ន មិនបណ្តែតបណ្តោយឲ្យកំហុសចាស់ពីអតីតកាលអាចកើតមាន និង អាចឲ្យមហាសោកនាដកម្មវិលកើតជាថ្មីឡើងវិញបាន ។ ខ្ញុំសង្ឃឹមថា អំពើខុសឆ្គង ឬ ភាពអន់ថយ ឬ ចំណុចខ្សោយទាំងប៉ុន្មានពីអតីតកាលនោះ អាចនឹងជួយដាស់តឿនក្រើនរំលឹកយើងរាល់គ្នា ឲ្យប្រុងប្រយ័ត្នជានិច្ច ។